ជំនួយស្មារតី

# សទ្ទានុក្រមរបៀបប្រើពាក្យ

សាស្ត្រាចារ្យ ទូច-តីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

ជំនួយស្មារតី

# សទ្ទានុក្រមរបៀបប្រើពាក្យ

សាស្ត្រាចារ្យ ទូច-តឹមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

# សទ្ទានុក្រមរបៀបប្រើពាក្យ


រៀបរៀង : លោក **ទូច-គីមស្រ៊ាង** បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

ជំនួយការ : លោក **អ៊ុន-សុភា** បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **លីម-ថេង** សោតណោ

: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវង្ស**

: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អឿ-សាវ៉ន**

: លោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀង

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះមហា **វ៉ែន-វិបុល** : លោក **អៀង-ពិសី**

: កញ្ញា **ផៃ-សារ៉ែម** : កញ្ញា **ចាន់-នីតា**

: កញ្ញា **ធិញ-ធីណា** : លោក **ឆោត-ច័ន្ទវិបុល**

: លោក **វ៉ាន់-ផល្លី** : លោក **ប៊ុត-សុផល**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន** រោងពុម្ព JSRC Printing House



ISBN-9 789996 370557



រក្សាសិទ្ធិគ្រប់យ៉ាង ©



បោះពុម្ពលើកទី១ : ១៣កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

: ត្រូវនឹងថ្ងៃសៅរ៍ ទី៦ ខែកញ្ញា គ.ស. ២០១៤

ឧបត្ថម្ភបោះពុម្ព : **សប្បុរសជន**

អាសយដ្ឋានចែកចាយ : បណ្ណាល័យ សកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ...



*“ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់”*

# **អារម្ភកថា**

សៀវភៅ សទ្ទានុក្រមរបៀបប្រើពាក្យ នេះដែលព្រះតេជព្រះគុណ សម្តេច ទ្រង់ ឯកឧត្តម ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ប្រិយមិត្ត កំពុងតែអាន ខ្ញុំបានប្រើពេលវេលាយ៉ាងយូរក្នុងការរៀបរៀងសៀវភៅនេះឡើង ដោយគោលបំណងបំពេញទៅតាមសំណូមពរលោកគ្រូ អ្នកគ្រូ និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដើម្បីយល់ដឹងពីគំនិតល្អៗជាច្រើនពី សទ្ទានុក្រមរបៀបប្រើពាក្យ ដែលមនុស្សទូទៅមិនទាន់បានយល់ដឹងទៅលើការប្រើពាក្យនិងមិនសូវចេះប្រើពាក្យទាំងនោះឱ្យបានត្រឹមត្រូវតាមលក្ខណៈវេយ្យាករណ៍ខ្មែរនៅឡើយ។

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយតាំងពីអតីតកាល មករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យ បទពិសោធ ទស្សនៈបុរាណ ទស្សនៈថ្មីៗ ដើម្បីចូលរួមចំណែកអភិរក្សនិងអភិវឌ្ឍវិស័យភាសាខ្មែរយើង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមែកធាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ និងជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំរង់ចាំទទួលយកកំហុសឆ្គងដោយសុច្ឆន្ទៈ មនសិការសោមនស្សគំនិតកែលម្អពីសំណាក់លោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ។

រាជធានីភ្នំពេញ ១៣កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃសៅរ៍ ទី៦ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាច**

## **កតញ្ញូកតវេទិតាធម៌**

កូនសូមក្រាបថ្វាយបង្គំលើកហត្ថាប្រណាម្យឧទ្ទិសស្នាដៃនេះ ជូនចំពោះលោកឪពុក **ទ្រី-យ៉េន** និងអ្នកម្តាយ **អ៊ុំ-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃជីវិតកូន។

កូនសូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេ ដែលបានផ្តល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះរូបកូនចងចាំអស់មួយជីវិតហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្តោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើពេលវេលាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមគោរពសច្ចាប្រណិធានប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងរហូត។

រាជធានីភ្នំពេញ ១៣កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃសៅរ៍ ទី៦ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ឌួច-គីមស្រ៊ាង**

**ឧទ្ទិសកថា**

សូមឧទ្ទិសស្នាដៃនេះគោរពថ្វាយ ប្រគេន ជូនចំពោះ

❖ បុព្វបុរសខ្មែរស្នេហាជាតិដែលបានធ្វើពលិកម្មគ្រប់យ៉ាងការពារជាតិមាតុភូមិ

❖ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

❖ សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្ដដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

❖ បុព្វការីជនរបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ច។

រាជធានីភ្នំពេញ ១៣កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃសៅរ៍ ទី៦ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាង**

## នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការខារធម្មទាន
## ដើម្បីដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

| | |
|---|---|
| - **មូលនិធិអៀង** | **មណ្ឌលព័ត៌មានស្ត្រីកម្ពុជា** |
| - CAM-PAINT **ថ្នាំពណ៌ជាត** | **ក្រុមហ៊ុន ភ្នំពេញ លេប័រ សីបផ្លាយ** |
| - លោក **សោម-សម្បត្តិ** | និង លោកស្រី **អ៊ុក-ចន្ថា** |
| - មហាឧបាសិកា **សុខ-អ៊ីម** | និង បុត្រ **ឝ្ង-ឆៃគៀង** |
| - ឧបាសក **អៀង-អឿន** | និង ឧបាសិកា **អៀង-សាតីម** |
| - ឯកឧត្តម **តេង-សាវង្ស** | និង លោកជំទាវ **ស៊ាង-តីម** |
| - ឯកឧត្តម **ម៉ម-សំ** | និង លោកជំទាវ **អ៊ិត-បុប្ផាផល្គុណ** |
| - ឯកឧត្តម **អឿ-សាវ៉ន** | និង លោកជំទាវ **ពៅ-សារឿន** |
| - ឯកឧត្តម **ប៉ែន-វចិត្រ** | និង លោកជំទាវ **ដេន-សុភ័ក្រនារី** |
| - ឯកឧត្តម **តាង-ហៀង** | និង លោកជំទាវ **លី-គីមមួយ** |
| - ឯកឧត្តម **ចាន់-សារ៉េត** | និង លោកជំទាវ **ស៊ឹម-ថារី** |
| - ឯកឧត្តម **ស៊ិន-ឌីម** | និង លោកជំទាវ **ប៉េង-ហ៊ាង** |
| - ឯកឧត្តម **ពេជ-សាធឿន** | និង លោកជំទាវ **ឈិម-ស៊ីថន** |
| - លោក **នុត-រ៉ានី** | និង លោកស្រី **អ៊ុន-សោភា** |
| - លោក **នុត-ទុន្តី** | និង លោកស្រី **កែន-ប៊ុណ្ណា** |
| - លោក **អេង-យូលីម** | និង លោកស្រី **ឧន់-ហ៊្គិចហ្វួយ** |
| - លោក **នួន-សុខា** | និង លោកស្រី **អ៊ូច-វណ្ណាថា** |
| - លោក **ឡុង-និត្យ** | និង លោកស្រី **ពេជ្រ- ណារី** |
| - លោក **យិន-សារិទ្ធ** | និង លោកស្រី **ឡឿន-សុគន្ធា** |

- លោក **គង់-សន្តារិន** និង លោកស្រី **ឱត្យ-តារា**

- លោក **ឆាង-សុជីវី** និង លោកស្រី **ហ៊ាង-ឆវី**

- លោក **អេង-ហ៊ី** និង លោកស្រី **លឹម-ខេង**

- លោក **ហ៊ឹង-បូរ៉ា** និង លោកស្រី **អួម-សោភា**

- លោក **ចាច-វណ្ណា** និង លោកស្រី **ម៊ី-សុខឌី**

- លោក **ចួន-ឆូ** និង លោកស្រី **ហ៊ុត-ដានី**

- លោក **គុយ-វ៉ាត** និង លោកស្រី **ឌុយ-តីន**

- លោក **អ៊ួង-គឹមសេង** និង លោកស្រី **ជា-លីណា**

- លោក **គឹម-ប៊ុន្នី** និង លោកស្រី **សុភ-ស្រី**

- លោក **អន-ប៊ុនណា** និង លោក **លួ-រ៉ាប៊ូ**

- សាស្ត្រាចារ្យ **ហ៊ុយ-សូវ៉ាត** និង លោកស្រី **សាត-ដាន់ណា**

- លោក **យាង-ច័ន្ទវិឡា** និង លោកស្រី **លី-ហាក់ហៀង**

- ឧបាសក **វ៉ាក់-ហ៊ាង** និង ឧបាសិកា **ម៉ឹង-សឿន**

- លោក **ប៊ូ-គឹមលាង** និង លោកស្រី **ឈឹម-ស៊ីយ៉ាន**

- លោក **ឆួន-ហ៊ាន** នាយកសាលាប៉ែលធីទី៦ និង លោកស្រី **ឈឹម-ច័ន្ទកែវ**

- លោក **ចាន់-ឱតា** នាយកសាលាប៉ែលធីទី៥ និង លោកស្រី **ជឹម-ស្រីមនោ**

- លោក **សូវ៉ាត-ឥស្ថា** នាយកសាលាប៉ែលធីទី១ និង លោកស្រី **ឈឹម-ឡាលីន**

- លោក **គឹម-វីរៈ** នាយកសាលាប៉ែលធីទី១៣ និង លោកស្រី **តូ-ជីន ជីន**

- លោក **យូ-រ័ត្ន** និង លោកស្រី **ណាំ-មួយជូ**

- លោក **ច្រឹក-សុខនីម** និង លោកស្រី **ហៀង-ឆវី**

- ឧបាសិកា **ហេង-ហ៊ាង** និង **កូនចៅ ហេង ចំណូល**

# **សេចក្តីថ្លែងអំណរគុណ**

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្តមភរិយា **ប៉ែន-សេងយ៉ុង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានឃោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស សូមគោរពសម្តែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សប្បុរសជន** ដែលមានសន្តានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ពសៀវភៅ សទ្ទានុក្រមរបៀបប្រើពាក្យ ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីផលប្រយោជន៍នៃគុណតម្លៃវប្បធម៌ ភាសា អក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

សូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ សប្បុរសជន និងលោកអ្នកអានដែលបានជួយលើកស្ទួយគុណតម្លៃរៀបរៀងសៀវភៅរបស់ខ្ញុំ និងសូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុស ដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។

រាជធានីភ្នំពេញ ១៣កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃសៅរ៍ ទី៦ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ឡូច-គីមស្រ៊ាង**

## អក្សរសង្ខេប

ប្រើក្នុងសទ្ទានុក្រមរបៀបប្រើពាក្យនេះ

| | | |
|---|---|---|
| *កិ.* | : | កិរិយាសព្ទ |
| *កិ. វិ.* | : | កិរិយាវិសេសន៍ |
| *គ.ម.* | : | គីឡូម៉ែត្រ |
| *គ.ស.* | : | គ្រិស្តសករាជ |
| *គុ.* | : | គុណសព្ទ |
| *ដ.ម.* | : | ដេស៊ីម៉ែត្រ |
| *ដា.ម.* | : | ដេកាម៉ែត្រ |
| *ន.* | : | នាមសព្ទ |
| *និ.* | : | និបាត |
| *បា.* | : | បាលី |
| *បា.សំ.* | : | បាលីនិងសំស្ក្រឹតលាយគ្នា |
| *បុ.ស.* | : | បុរិសសព្វនាម |
| *ព.កា.* | : | ពាក្យកាព្យ |
| *ព.គ.* | : | ពាក្យគួរសម |
| *ព.ច្បាប់* | : | ពាក្យច្បាប់ |
| *ព.ទ.បុ.* | : | ពាក្យទំនឹមបុរាណ |
| *ព.បុ.* | : | ពាក្យបុរាណ |
| *ព.ប្រ.* | : | ពាក្យប្រៀប (ពាក្យប្រើចំពោះ) |

| | | |
|---|---|---|
| *ព.ផ្ទ.* | : | ពាក្យផ្ទុយ |
| *ព.ស.* | : | ពុទ្ធសករាជ |
| *ព.ស.ស.* | : | ពាក្យដែលប្រើក្នុងសម័យសព្វថ្ងៃនេះ |
| *ព.សា.* | : | ពាក្យសាមញ្ញ (ពាក្យធម្មតា ឬ ពាក្យផ្សារ) |
| *ម.* | : | ម៉ែត្រ |
| *ម.២* | : | ម៉ែត្រការ៉េ |
| *ម.៣* | : | ម៉ែត្រគុប |
| *ម.ម.* | : | មិល្លីម៉ែត្រ |
| *យ.* | : | យួន |
| *រ.ស.* | : | រាជសព្ទ |
| *វេវ.* | : | វេវចនៈ |
| *ស.* | : | សៀម (ភាសាសៀម) |
| *ស.ម.* | : | សង់ទីម៉ែត្រ |
| *សំ.ស.* | : | សំស្រ្កឹតសន្មត |
| *ហ.ម.* | : | ហិកតូម៉ែត្រ |
| *អ.ថ.* | : | អានថា |
| *អា.និ.* | : | អាយតនិបាត |
| *ឧ.* | : | ឧទាហរណ៍ |

# សទ្ធានុក្រមរបៀបប្រើពាក្យ

**កង្វល់** *ន.* សេចក្ដីខ្វល់ចិត្ត, សេចក្ដីខ្វល់គំនិត :

➢ **មានកង្វល់** (កុំប្រើថា សេចក្ដីកង្វល់ ព្រោះពាក្យនេះជា នាមនាម ប្រាប់សេចក្ដីខ្វល់ ស្រេចហើយ; បើចង់ប្រើពាក្យថា សេចក្ដី ត្រូវថា មានសេចក្ដីខ្វល់ ក៏គឺ មានកង្វល់ ហ្នឹងឯង)។

📖 **ខ្ញុំមានកង្វល់** កុំប្រើថា ខ្ញុំមានសេចក្ដីកង្វល់។

➢ **មានកង្វល់** កុំប្រើថា មានការកង្វល់ ដូច្នេះឡើយ។

➢ **មានកង្វល់** កុំប្រើថា មានក្ដីកង្វល់ ដូច្នេះឡើយ។

➢ **មានកង្វល់** កុំប្រើថា មានសេចក្ដីកង្វល់ ដូច្នេះឡើយ។

➢ **អស់កង្វល់** កុំប្រើថា អស់ការកង្វល់ ដូច្នេះឡើយ។

➢ **អស់កង្វល់** កុំប្រើថា អស់ក្ដីកង្វល់ ដូច្នេះឡើយ។

➢ **អស់កង្វល់** កុំប្រើថា អស់សេចក្ដីកង្វល់ ដូច្នេះឡើយ។

**មានកង្វល់** : មានក្ដីខ្វល់។

**ស្រុកកើតកង្វល់** : ស្រុកដែលមានកើតសឹកសង្គ្រាមឬមានកើតបះបោរចលាចលអ្វី។

**កំណាត់** *ន.* អ្វីៗដែលគេកាត់, អ្វីៗដែលដាច់ដាច :

❖ កំណាត់ឈើ

❖ ឫស្សីមួយកំណាត់។

**កំណាត់សំពត់** : សំពត់ចាស់ដាច់ដាចសម្រាប់ជូតអ្វីៗជា សំពត់ជយថោក។

ឯ សំពត់ថ្មី ដែលគេកាត់ហើយ ហៅតាមខ្នាតនោះថា :

- សំពត់មួយអាវ
- សំពត់ប្រវែងពីរម៉ែត្រ
- សំពត់មួយត្បូងឬហៅថាសំពត់មួយម៉ែត្រ។

បើសំពត់វែងហៅថា សំពត់មួយគី, សំពត់មួយផាប់, ខ្មែរក្នុងសម័យបុរាណពុំដែលហៅ សំពត់ថ្មី ដែលគេកាត់ហើយនោះថា កំណាត់ ឡើយ, ហៅ កំណាត់ ចំពោះតែសំពត់ចាស់សម្រាប់ជូតអ្វីៗដែលប្រឡាក់, ដែលសៅហ្មងប៉ុណ្ណោះឯង។

**ខួប** *ន.* រវាងពេលថ្ងៃខែឆ្នាំដែលមកជួបគ្នាវិញ :

- **មួយខួបពេល២៤ម៉ោង** គឺ មួយថ្ងៃមួយយប់
- **មួយខួបថ្ងៃ៧** គឺ មួយសប្ដាហ៍
- **មួយខួបខែ១២** គឺ មួយឆ្នាំ
- **មួយខួបឆ្នាំ១២** គឺ មួយជុំរាសីឆ្នាំ។

**ខ្ញុំ១** *ទុ.ស.* សម្ដីដែលសាមីខ្លួនហៅខ្លួនឯង :

- ខ្ញុំសុំអញ្ជើញបងទៅក្រុងព្រះសីហនុជាមួយនឹងខ្ញុំបាន៣ថ្ងៃ។

**ខ្ញុំបាទ** : សម្រាប់និយាយជាមួយនឹងមន្ត្រីដែលមាន សក្តិមធ្យម ឬ ជាមួយនឹងមនុស្ស ឥតយសសក្តិ ទេប៉ុន្តែគួរគោរព។ បើស្ត្រីថា នាងខ្ញុំ។

**ខ្ញុំព្រះបាទ** : សម្រាប់និយាយជាមួយនឹងមន្ត្រីដែលមាន សក្តិធំ។ បើស្ត្រីថា នាងខ្ញុំ។

**ខ្ញុំឯង** : ជាព្រះរាជឱង្ការនៃព្រះមហាក្សត្រដែលទ្រង់ប្រាស្រ័យជាមួយនឹងប្រជាពលរដ្ឋដោយការគួរសម; បើព្រះរាជឱង្ការពុំគួរសមទេ ដូចអ្នកបម្រើបម្រាស់ស្និទ្ធជិតព្រះអង្គជាដើមថា អញ ឬ អញឯង...។

**បញ្ជិតថា**

**អាត្មា** : សម្រាប់និយាយជាមួយនឹង ពុំមែនឥស្សរជន។

**អាត្មាភាព** : សម្រាប់និយាយជាមួយនឹង ឥស្សរជន។

☞ បុរាណថា អាចក្តី :

❖ អាចក្តីពុំស្វរសប្បាយ ចេះតែវិលមុខ។

**ខ្ញុំ២** *ន.* មនុស្សដែលកំដឹងទ្រព្យគេ គឺមនុស្សដែលទ័លក្រហើយទៅខ្ចីទ្រព្យគេមកចិញ្ចឹមជីវិត រកសងគេមិនបានយកខ្លួនទៅនៅបម្រើគេឬមាតាបិតាជំពាក់ទ្រព្យគេឱ្យកូនទៅនៅបម្រើគេ, កូននោះក៏ឈ្មោះថា ខ្ញុំគេ :

❖ មនុស្សខ្ញុំគេ (មានតែពីដើម, ក្នុងសម័យនេះលើកលែងមិនឱ្យមាន; ពាក្យគួរសមហៅជាភាសាបាលីថា **ទាសា**, **ទាសី** "ខ្ញុំប្រុស, ខ្ញុំស្រី")។

**ខ្ញុំព្រះអង្គ** *(ព.ប្ញ.)* *ប្ញ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូល ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ខ្ញុំព្រះអង្គក្រោមព្រះតេជះ** *(ព.ប្ញ.)* *ប្ញ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូល ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ខ្ញុំព្រះអង្គក្រោមល្អងធូលីព្រះបាទ** *(ព.ប្ញ.)* *ប្ញ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូល ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

📖 **កំណត់ចំណាំ** :

- **ខ្ញុំព្រះអង្គក្រោមព្រះតេជះ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ជាង ខ្ញុំព្រះអង្គ។
- **ខ្ញុំព្រះអង្គក្រោមល្អងធូលីព្រះបាទ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ក្រៃលែង ជាង ខ្ញុំព្រះអង្គក្រោមព្រះតេជះ ទៅទៀត។

**ខ្ញុំម្ចាស់** *ប្ញ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់ស្ត្រីហៅ ខ្លួនឯង និយាយក្រាបទូល ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ខ្ញុំម្ចាស់ក្រោមព្រះតេជះ** *(ព.ប្ញ.)* *ប្ញ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់ស្ត្រីហៅ ខ្លួនឯង និយាយក្រាបទូល

ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ខ្ញុំម្ចាស់ក្រោមល្អងធូលីព្រះបាទ** *(ព.ម្ទ.) ម្ទ.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

❀ ពាក្យប្រើក្នុងរាជសព្ទសម្រាប់ស្ត្រីហៅ **ខ្លួនឯង** និយាយក្រាបទូល ចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**កំណត់ចំណាំ** :

**ខ្ញុំម្ចាស់ក្រោមព្រះតេជះ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ជាង ខ្ញុំម្ចាស់ ។

**ខ្ញុំម្ចាស់ក្រោមល្អងធូលីព្រះបាទ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ក្រៃលែង ជាង ខ្ញុំម្ចាស់ក្រោមព្រះតេជះ ទៅទៀត។

**គម្រប់១** *កិ.* ធ្វើឱ្យគ្រប់, បង្គ្រប់, បំពេញឱ្យគ្រប់ :

❖ មាន៣ហើយត្រូវថែម២មកទៀតគម្រប់ជា៥ (ច្រើនប្រើបង្គ្រប់ជាង)។

**គម្រប់២** *គុ.* ដែលជាទីបង្គ្រប់ចំនួន :

❖ **គម្រប់២** គឺ ទី២

❖ **គម្រប់៣** គឺ ទី៣

❖ **គម្រប់៤** គឺ ទី៤

ប៉ុន្តែកុំប្រើ **គម្រប់១** ព្រោះមួយជា បូរណសំខ្យាទោលឯកឯង, ត្រូវប្រើជា **ទី១** ឬជា **បឋម**, ជា **ប្រថម**, ជា **ដំបូង**។

**គឺ១** *ធ.* ពាក្យសម្រាប់និយាយខែពាក្យ ខែសេចក្ដីដែលមានន័យមានទំនងស្មើគ្នា ដើម្បីឱ្យច្បាស់ :

❖ **សម្រាន្ត** គឺ ដេក

❖ **មិនចាំ** គឺ ភ្លេច

❖ **មិនល្អ** គឺ អាក្រក់

❖ **មិនចេះ** គឺ ល្ងង់។

ប្រាប់ដំណើរសម្រេចអំពើរបស់អ្នកធ្វើមានសេចក្ដីថា ដែល :

**ការទុះគឺខ្ញុំធ្វើ** : ការទុះដែលខ្ញុំធ្វើ។

សម្រាប់និយាយសរុប, ប្រមូលអ្វីៗដែលរួបរួម រាយឈ្មោះឱ្យឃើញតាមចំនួន :

ឥរិយាបថមាន៤យ៉ាងគឺ

❖ ដើរ

❖ ឈរ

❖ អង្គុយ

❖ ដេក; បើមិនប្រើពាក្យថា គឺ នឹងប្រើសរសេរគ្រឿងសម្គាល់ (:) នេះជាជំនួសក៏បាន, ដូច្នេះឥរិយាបថមាន៤ :

❖ ដើរ

❖ ឈរ

❖ អង្គុយ

❖ ដេក, មានសេចក្ដីដូចគ្នានឹង គឺ ដែរ។

**តឹ២** *ន. (យ.)* រង្វាស់សម្រាប់វាស់ ឱស បណ្ដោយ១០ម៉ែត្រ ទទឹង១ម៉ែត្រ កម្ពស់១ម៉ែត្រ :

❖ ឧស១តឹ។

❀ *ន.* ភស្ដុតាងដែលមែន, ប្រាកដ, ជាក់ :

❖ ដូចមានខ្លួនឈ្មោះនោះនៅជាតឹស្រាប់

❖ សឹងមានឪពុកខ្ញុំជាតឹ។

**តេខ** *កិ.* ប្រះដេក, ប្រះដេកឱ្យឮគ្រេង; ពាក្យទំយើ, ពាក្យផ្អែមសម្រាប់និយាយចំពោះកូនតូចដែលទើបនឹងចេះអង្គុយឬទើបនឹងចេះដើរដួល :

❖ នាងគេងទៅ

❖ ហ៏កូនម៉ែគេងទៅ!។

**ខាប់** *កិ.* ឬ *គុ.* ស្លាប់, គាំង។

📖 និយាយចំពោះតែ អនុបាទិន្នគរូប មានឈើនិងគ្រឿងចក្រជាដើម :

❖ ឈើងាប់

❖ ឫស្សីងាប់

❖ នាឡិកាងាប់។

📖 បើចំពោះ ឧបាទិន្នគរូប មានមនុស្សជាដើម គឺជាពាក្យទ្រគោះ :

❖ អាចោរកំណាចនោះវាងាប់ទៅហើយ។

📖 ចំពោះសត្វតិរច្ឆាន :

❖ គោងាប់

❖ ក្របីងាប់

❖ ជ្រូកងាប់

❖ ពពែងាប់។

**ងាប់គំនិត** គឺផុត, ទាល់អស់ផ្លូវគិតតទៅទៀត។

**ពាក្យគួរសម៧** :

❖ ស្លាប់គំនិត

❖ ផុតគំនិត

❖ ទាល់គំនិត

❖ អស់គំនិត។

**ចំពោះ** ***អ.និ. ឬ កិ.វិ.*** ដោយចំ, ឆ្ពោះ, ត្រង់, សំដៅត្រង់, សំដៅលើ, ដល់, នា :

| | | |
|---|---|---|
| ❖ **ជូនចំពោះ** | កុំប្រើថា | ជូនដល់ |
| ❖ **ថ្វាយចំពោះ** | កុំប្រើថា | ថ្វាយដល់ |
| ❖ **បូជាចំពោះ** | កុំប្រើថា | បូជាដល់ |
| ❖ **ឧទ្ទិសចំពោះ** | កុំប្រើថា | ឧទ្ទិសដល់។ |

ពាក្យ ចំពោះ សម្រាប់និយាយជាមួយនឹង ក្សត្រ និង ឥស្សរជន, កុំប្រើពាក្យ ដល់ សម្រាប់និយាយជាមួយនឹង ក្សត្រ និង ឥស្សរជន ឡើយ។

**ឆ្នាំ** *ន.* កំណត់វេលាមួយខួបខែ១២។

- **ឆ្នាំទៅ** : ឆ្នាំដែលកន្លងទៅហើយបន្ទាប់ឆ្នាំបច្ចុប្បន្ននេះ។
- **ឆ្នាំទៅមួយ** : ឆ្នាំដែលកន្លងទៅហើយមុនឆ្នាំទៅ។
- **ឆ្នាំទៅមួយនាយ** : ឆ្នាំដែលកន្លងទៅហើយមុនឆ្នាំទៅមួយ។
- **ឆ្នាំក្រោយ** : ឆ្នាំមុខ, ឆ្នាំខាងមុខ។

**ជាវ** *កិ.* លក់ឬទិញ (ពាក្យគោរព) :

- ជាវដី
- ជាវគម្ពីរ
- ជាវត្រៃចីវរ
- ជាវព្រះពុទ្ធរូប។

**ជូន១** *កិ.* បូជា, ឱ្យ (ពាក្យគោរព, ពាក្យគួរសម) :

- របស់នេះខ្ញុំមិនលក់ដូរទេ ខ្ញុំជូនលោក។

ទៅមកជាមួយកំដរជាគ្នា :

- ស្អែកខ្ញុំមានរវល់នឹងជូនប្អូនខ្ញុំទៅខេត្តកំពង់ស្ពឺ។

**ជូន២** *កិ.* លើក! ឯងចូរលើកជើងឡើង! ពាក្យស្រែកបង្គាប់ឱ្យដំរីលើកជើងដើម្បីនឹងជាន់ឡើងឬជាន់ចុះ។

**ជំនួប** *ន.* ការដែលជួប, ដំណើរជួប។

↳ **មានជំនួប** (កុំប្រើថា ការជំនួប, ដំណើរជំនួប ព្រោះពាក្យនេះជា

នាមនាម ប្រាប់ ការជួប, ដំណើរជួប ស្រេចហើយ; បើចង់ប្រើពាក្យថា ការ, ដំណើរ ត្រូវថា មានការជួប, មានដំណើរជួប ក៏គឺ មានជំនួប ហ្នឹងឯង)។

↳ **មានជំនួប** កុំប្រើថា មានការជំនួប ដូច្នេះឡើយ។

↳ **មានជំនួប** កុំប្រើថា មានក្ដីជំនួប ដូច្នេះឡើយ។

↳ **មានជំនួប** កុំប្រើថា មានសេចក្ដីជំនួប ដូច្នេះឡើយ។

↳ **អស់ជំនួប** កុំប្រើថា អស់ការជំនួប ដូច្នេះឡើយ។

↳ **អស់ជំនួប** កុំប្រើថា អស់ក្ដីជំនួប ដូច្នេះឡើយ។

↳ **អស់ជំនួប** កុំប្រើថា អស់សេចក្ដីជំនួប ដូច្នេះឡើយ។

**ជំនួយ** *ន.* ការជួយ, អំពើដែលជួយ; របស់ដែលគេឱ្យដោយជួយ, អ្វីៗដែលគេជួយ; អ្នកជួយ :

- ខ្វះជំនួយ
- មានជំនួយ។

↳ **មានជំនួយ** (កុំប្រើថា ការជំនួយ, ព្រោះពាក្យនេះជា នាមនាម ប្រាប់ ការជួយ ស្រេចហើយ; បើចង់ប្រើពាក្យថា ការ ត្រូវថា មានការជួយ ក៏គឺ មានជំនួយ ហ្នឹងឯង)។

↳ **ខ្វះជំនួយ** កុំប្រើថា ខ្វះការជំនួយ ដូច្នេះឡើយ។

↳ **ខ្វះជំនួយ** កុំប្រើថា ខ្វះក្ដីជំនួយ ដូច្នេះឡើយ។

↳ **ខ្វះជំនួយ** កុំប្រើថា ខ្វះសេចក្ដីជំនួយ ដូច្នេះឡើយ។

➢ **មានជំនួយ** កុំប្រើថា មានការជំនួយ ដូច្នេះឡើយ។

➢ **មានជំនួយ** កុំប្រើថា មានក្ដីជំនួយ ដូច្នេះឡើយ។

➢ **មានជំនួយ** កុំប្រើថា មានសេចក្ដីជំនួយ ដូច្នេះឡើយ។

➢ **អស់ជំនួយ** កុំប្រើថា អស់ការជំនួយ ដូច្នេះឡើយ។

➢ **អស់ជំនួយ** កុំប្រើថា អស់ក្ដីជំនួយ ដូច្នេះឡើយ។

➢ **អស់ជំនួយ** កុំប្រើថា អស់សេចក្ដីជំនួយ ដូច្នេះឡើយ។

❀ ប្រើជា *ន.* ក៏បាន :

❖ ប្រាក់ជំនួយ។

**ជំនឿ** *ន.* សេចក្ដីដែលគួរជឿ, ដំណើរជឿ។

➢ **មានជំនឿ** (កុំប្រើថា សេចក្ដីជំនឿ, ដំណើរជំនឿ ព្រោះពាក្យនេះជា នាមនាម ប្រាប់ សេចក្ដីជឿ, ដំណើរជឿ ស្រេចហើយ; បើចង់ប្រើពាក្យថា សេចក្ដី, ដំណើរ ត្រូវថា មានសេចក្ដីជឿ, មានដំណើរជឿ ក៏គឺ មានជំនឿ ហ្នឹងឯង)។

➢ **មានជំនឿ** កុំប្រើថា មានការជំនឿ ដូច្នេះឡើយ។

➢ **មានជំនឿ** កុំប្រើថា មានក្ដីជំនឿ ដូច្នេះឡើយ។

➢ **មានជំនឿ** កុំប្រើថា មានសេចក្ដីជំនឿ ដូច្នេះឡើយ។

➢ **អស់ជំនឿ** កុំប្រើថា អស់ការជំនឿ ដូច្នេះឡើយ។

➢ **អស់ជំនឿ** កុំប្រើថា អស់ក្ដីជំនឿ ដូច្នេះឡើយ។

➢ **អស់ជំនឿ** កុំប្រើថា អស់សេចក្ដីជំនឿ ដូច្នេះឡើយ។

**ជំនុំ១** ***កិ.*** ពិគ្រោះគ្នាក្នុងវេលាជួបជុំ, ពិភាក្សាគ្នាក្នុងវេលាជួបជុំ :

❖ ជំនុំក្ដី

❖ ជំរះក្ដី។

✎ **ជំនុំជម្រះ** : ជំនុំឱ្យជ្រះស្រលះ។

**ជំនុំ២** ***ន.*** ទីប្រជុំជន, ភូមិ, តំបន់ដែលមានមនុស្សច្រើន, ក្រុង :

❖ ទីជំនុំ

❖ ស្រុកជំនុំ

❖ កណ្ដាលជំនុំ។

**ជំនុំ៣** ***អ.និ.*** បណ្ដា; ពាក្យសម្រាប់ប្រើដកវែកចំនួននីមួយៗអំពីចំនួនច្រើនឱ្យដាច់ដោយឡែក :

❖ ជំនុំអ្នកនគរទាំងមូល ព្រះមហាក្សត្រជាធំបំផុត

❖ ជំនុំមនុស្សទាំង១០នាក់នេះ ត្រូវចាត់មនុស្ស៣នាក់ឱ្យនៅចាំផ្ទះ។

**ជ្រាប១** ***កិ.*** ចូលសព្វសាច់, ហូរស្រក់ :

❖ ទឹកជ្រាប។

**ជ្រាប២** ***កិ.*** ដឹង :

❖ **សូមទ្រង់ជ្រាប** កុំប្រើថា សូមទ្រង់ដឹង ដូច្នេះឡើយ។

❖ **សូមទានជ្រាប** កុំប្រើថា សូមទានដឹង ដូច្នេះឡើយ។

❖ **សូមជ្រាប** កុំប្រើថា សូមដឹង ដូច្នេះឡើយ។

❖ **បានជ្រាប** កុំប្រើថា បានដឹង ដូច្នេះឡើយ។

📖 **កំណត់ចំណាំពាក្យ** ជ្រាប សម្រាប់ប្រើចំពោះតែអ្នកដទៃ។

**ញោម** *ទុ.ស.* ពាក្យសម្រាប់បព្វជិតហៅមាតាបិតាបង្កើតឬមាតាបិតាចិញ្ចឹម :

**ញោមប្រុស** គឺ ឪពុក។

**ញោមស្រី** គឺ ម្ដាយ។

ម្យ៉ាងទៀតឧបាសកឧបាសិកាឯទៀតៗដែលមានចំណាស់ប្រហែលនឹងមាតាបិតារបស់ខ្លួន បព្វជិតក៏ហៅ ញោម បានដែរ។

**ញាតិញោម** *ន.* ពាក្យសម្រាប់បព្វជិតហៅពួកឧបាសកឧបាសិកាទាយកទាយិកាដោយរួបរួម :

❖ វត្តនេះមានញាតិញោមជើងវត្តតិចណាស់

❖ សូមឱ្យញាតិញោមខំរៀនធម៌ កាន់សីល ប្រព្រឹត្តសុចរិត តាំងចិត្តស្លូតត្រង់គ្រប់គ្នាឡើងនឹងបានសេចក្ដីសុខចម្រើនកើនឡើងទៀត។

**ញាំុ** *កិ.* ស៊ី; និយាយបានតែចំពោះកូនក្មេងតូច (ពាក្យទំយើ) :

❖ វាចេះញុំាបាយខ្លួនវាហើយ។

**ដង្ហែ** *កិ.* ឬ *កិ.វ.* រៀបរៀងគ្នាជាជួរតាមមុនក្រោយ មើលទៅឃើញមានរបៀបហូរហែ :

❖ ដើរដង្ហែគ្នារជយ។

**ដល់១** ***អ.និ.*** ចំពោះ, ឆ្ពោះត្រង់, សំដៅឆ្ពោះ, ដែលផ្គងឆ្ពោះ, ...ដូចជា :

❖ ខ្ញុំនឹកដល់ម្តាយខ្ញុំណាស់

❖ គេឱ្យទានដល់ពួកស្មូម

❖ ពីម្សិលមិញខ្ញុំបានឱ្យប្រាក់មួយម៉ឺនរៀលដល់វាហើយ។

❀ សម្រាប់ព្រះមហាក្សត្រនិងឥស្សរជនឯទៀតៗ, ត្រង់ពាក្យ ដល់ នេះត្រូវប្រើពាក្យ ចំពោះ ឬ ឆ្ពោះ ជាជំនួស :

❖ សូមជូនពរចំពោះអស់លោក...

❖ សូមថ្វាយសាធុការចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង...។

❀ ដរាបទៅទល់នឹង :

❖ ចាំដល់ថ្ងៃស្អែកសឹមយើងទៅ

❖ ចុះដល់ទៅអង្កាល់?

❖ ចាំដល់ទៅអង្កាល់ក៏បាន!

❖ ចុះស៊ីដល់ណាទៅទៀត?។

📖 មួយទៀតត្រង់កន្លែង *(អ.និ.)* នៃ, កុំប្រើពាក្យ ដល់ :

❖ ព្រះអង្គជាម្ចាស់ប់ដ៏ត្រជាក់ ដល់ ប្រជាពលរដ្ឋទាំងពួង។

📖 ត្រូវប្រើថា :

❖ ព្រះអង្គជាម្លប់ដ៏ត្រជាក់ នៃ ប្រជាពលរដ្ឋទាំងពួងដូច្នេះវិញ។

📖 ដ្បិត នៃ ស្មើគ្នានឹង របស់ (ជាម្លប់របស់...)។

📖 គួរពិនិត្យឱ្យហ្មត់ចត់កុំប្រើដោយច្រឡំ *(អា.និ.)* ដល់, នឹង, នូវ, នៃ ដោយអាស្រ័យ :

➪ សកម្មកិរិយា

➪ អកម្មកិរិយា

➪ សកម្មាកម្មកិរិយាជាដើម ជាគោលផងជាដរាប។

**ដល់២** ***កិ.*** បានសម្រេច, បានទីដែលត្រូវទៅមក :

❖ គេបានទៅដល់ស្រុកគេហើយ។

**ដីកា** ***ន.*** គម្ពីរកែខែបញ្ជាក់អត្ថន័យរបស់បាលី ( បិដក) ខ្លះ, របស់អដ្ឋកថា នៃបាលីខ្លះ, របស់ដីកាមុនៗខ្លះ, អាងដល់អត្ថន័យរបស់គម្ពីរឯទៀតក៏មាន :

✍ គម្ពីរ **សារត្ថទីបនី** ជា មូលដីកា (ដីកាដើម)

✍ គម្ពីរ **វិមតិវិនោទនី** ជា អនុដីកា (ដីកាបន្ទាប់)

✍ គម្ពីរ **វជិរពុទ្ធិ** ជា អន្វានុដីកា (ដីកាបន្ទាប់ពីអនុដីកាមកទៀត) នៃវិនយបិដក។ ឯដីកាដែលកើតមានថ្មីៗតៗមកទៀតហៅថា នវដីកា (ដីកាថ្មី)។

📖 **ព្រះត្រៃបិដក** គឺ វិនយបិដក, សុត្តន្តបិដក, អភិធម្មបិដក សុទ្ធតែមានដីកាមានឈ្មោះផ្សេងៗគ្នា *(ព.ពុ.)*។

📖 ក្នុងបុរាណសម័យព្រេងនាយ, ប្រទេសកម្ពុជា ប្រើពាក្យថា ដីកា នេះច្រើនបែបមានដើម :

✎ **ដីកាកោះ** : លិខិតកោះហៅ...។

✎ **ដីកាបើក** : លិខិតបើកប្រាក់ឬវត្ថុផ្សេងៗ។

✎ **ដីកាសាទុក្ខ** : សម្រាប់ថ្វាយព្រះមហាក្សត្រជាអម្ចាស់ជីវិត, ដីកាសាទោស...។

✎ **សង្ឃដីកា** : លិខិតរបស់លោកចៅអធិការវត្តឬរបស់លោកគ្រូសូត្រ (ចំពោះតែការប្រើក្នុងផ្លូវការ)។ សព្វថ្ងៃនេះទោះលិខិតរបស់លោកមេគណ, អនុគណនិងមន្ត្រីសង្ឃឯទៀតក៏សុទ្ធតែហៅ *សង្ឃដីកា* ដូចគ្នា។

📖 លិខិតរបស់សម្តេចព្រះសង្ឃនាយកហៅ *ព្រះសង្ឃដីកា* (គួរបង្កើតពាក្យហៅថា *ព្រះសង្ឃនាយកដីកា* វិញដើម្បីឱ្យមានឈ្មោះផ្សេងអំពីលិខិតរបស់ព្រះរាជាគណៈទី *សម្តេច* ដែលត្រូវហៅថា *ព្រះសង្ឃដីកា* ដែរ)។ លិខិតរបស់សម្តេចព្រះសង្ឃរាជហៅថា *ព្រះសង្ឃរាជដីកា*។

**ដេក** *កិ.* សម្រេចឥរិយាបថ មួយ ផ្សេងអំពីឥរិយាបថ បី :

➢ ដើរ

➢ ឈរ

➢ អង្គុយ។

✍ គឺដាក់ខ្លួនដេកលើទី, បញ្ឈប់អារម្មណ៍សំងំឱ្យលក់។

📖 *(ព.ប្រ.)* ឈប់ដោយមានទាស់ដំណើរ, មិនប្រព្រឹត្តទៅ :

❖ រោងម៉ាស៊ីននុះឥឡូវដេកទៅហើយ។

**ដែល១** ***គុ.និ.*** ពាក្យប្រាប់ដំណើរនៃអំពើសម្រាប់និយាយភ្ជាប់នាំមុខនាមសព្ទ, គឺដូចពាក្យថា :

❖ ការដែលខ្ញុំធ្វើ

❖ ដំណឹងដែលខ្ញុំឮ

❖ ពាក្យដែលគេនិយាយ

❖ សាលារៀនដែលរាជការចំណាយប្រាក់ឱ្យសង់...។

**ដែល២** ***ន.*** សំណល់, របស់ដែលសល់ឬរបស់ដែលគេប្រើប្រាស់ហើយ :

❖ ស៊ីបាយដែលគេ

❖ ស្លៀកសំពត់ដែលគេ...។

**តម្លា** ***ន.*** ដំណើរធ្វើឱ្យថ្លា, សេចក្ដីថ្លា, សភាពដែលរងថ្លា :

**មានចិត្តកាត់តម្លាសទ្ធា** : មានចិត្តជ្រះថ្លាជឿ។

📖 ពាក្យ តម្លា នេះប្រើចំពោះតែចិត្តជាកុសល។

**តេជះ** ***ន.*** តេជ, អំណាច, អានុភាព, កម្លាំង; កម្ដៅ; ភ្លើង...។

❖ ដោយតេជះគុណបុណ្យជួយឱ្យបានសេចក្ដីសុខ។

**សូមព្រះតេជះតម្កល់លើត្បូង**! ជាពាក្យសម្រាប់ប្រើក្នុងសេចក្ដីផ្ដើមក្រាបបង្គំទូលព្រះមហាក្សត្រទ្រង់រាជ្យ :

❖ សូមព្រះតេជះតម្កល់លើត្បូង!

❖ សូមព្រះរាជទានទូលព្រះបង្គំជាខ្ញុំ ឧកញ៉ា... សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង សូមទ្រង់ជ្រាប...។

**ទិញ** *កិ.* បានអ្វីៗមកជារបស់ខ្លួនដោយឱ្យថ្លៃជាប្រាក់ទៅអ្នកលក់ :

❖ ទិញសំពត់

❖ ទិញសៀវភៅ។

**ទិញជឿ** : យករបស់គេមកមុនដោយទិញមិនទាន់សងថ្លៃ ព្រោះអ្នកលក់ជឿថា អ្នកទិញមុខជាសងថ្លៃមិនខាន។

**ទូលព្រះបង្គំ** *ប្ក.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូលចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ទូលព្រះបង្គំជាខ្ញុំ** *ប្ក.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូលចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ** *ប្ក.ស.* ខ្ញុំ, ខ្លួនខ្ញុំ។

ពាក្យប្រើក្នុងរាជសព្ទសម្រាប់បុរសហៅ ខ្លួនឯង និយាយក្រាបទូលចំពោះ ព្រះមហាក្សត្រ ឬចំពោះ ក្សត្រ ទាំងពួង។

**កំណត់ចំណាំ** :

**ទូលព្រះបង្គំជាខ្ញុំ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ជាង ទូលព្រះបង្គំ។

**ទូលព្រះបង្គំជាខ្ញុំក្រោមល្អងធូលីព្រះបាទ** ជាពាក្យគោរពដ៏ខ្ពង់ខ្ពស់ក្រៃលែងជាង ទូលព្រះបង្គំជាខ្ញុំ ទៅទៀត។

**ទើប** *និ.* និបាតសព្ទជាសន្ធានសម្រាប់និយាយបន្តសេចក្តីដោយឡែក, ប្រើបន្តពីឃ្លាសេចក្តីរបស់ពាក្យថា លុះតែ, ទាល់តែ, បើលុះតែ, កាលបើ..., ដូចជា :

- លុះតែគេសួរខ្ញុំទើបខ្ញុំឆ្លើយ
- លុះតែឱ្យតម្លៃគ្រប់ទៅគេទើបគេឱ្យរបស់ទាំងនោះមកយើង
- យប់មិញទាល់តែដល់ម៉ោង៣ទើបខ្ញុំទទួលទានដំណេក
- បើលុះតែបងព្រមទៅទើបគេទៅទាំងអស់គ្នា
- កាលបើយើងអញ្ជើញគេទើបគេនឹងមកទាំងអស់គ្នា។

☞ ទើបតែនឹង ឬ ទើបនឹង ជាសន្ធានប្រាប់អតីតកាលឈោងចូលមកក្នុងអនាគត :

- គេមកជួបជុំយូរដែរហើយ បងឯងទើបតែនឹងមកដល់ក្រោយគេ
- ខ្ញុំទើបនឹងមកពីខេត្តក្រៅ...។

☞ ទើបបាន ជាសន្ធានប្រាប់បច្ចុប្បន្នកាលជិតអនាគត :

- អើ, ធ្វើយ៉ាងហ្នឹងទើបបានពេញជាត្រូវ
- បើលុះតែលោកគ្រូនាំថាមុនទើបបានសិស្សថាតាមកើត...។

**ទោមនស្ស** *ន.* សេចក្តីតូចចិត្ត, សេចក្តីអាក់អន់ចិត្ត :

- មានទោមនស្ស

❖ ចិត្តប្រកបដោយទោមនស្ស។

📖 **មានទោមនស្ស** មិនបាច់ប្រើ សេចក្ដី ផ្សេងៗ សេចក្ដីទោមនស្ស ទេ។

➢ **មានទោមនស្ស** កុំប្រើថា មានការទោមនស្ស ដូច្នេះឡើយ។

➢ **មានទោមនស្ស** កុំប្រើថា មានក្ដីទោមនស្ស ដូច្នេះឡើយ។

➢ **មានទោមនស្ស** កុំប្រើថា មានសេចក្ដីទោមនស្ស ដូច្នេះឡើយ។

➢ **អស់ទោមនស្ស** កុំប្រើថា អស់ការទោមនស្ស ដូច្នេះឡើយ។

➢ **អស់ទោមនស្ស** កុំប្រើថា អស់ក្ដីទោមនស្ស ដូច្នេះឡើយ។

➢ **អស់ទោមនស្ស** កុំប្រើថា អស់សេចក្ដីទោមនស្ស ដូច្នេះឡើយ។

**ធនបត្រ** *ន.* ពាក្យសន្មតហៅក្រដាសដែលប្រើចាយជាជំនួសប្រាក់តាមបញ្ញត្តិរបស់រាជការគ្រប់ប្រទេសក្នុងសម័យសព្វថ្ងៃនេះ (ក្រដាសប្រាក់)។

☞ គួរប្រើពាក្យនេះតាមសម័យនិយម។

**ធ្ងន់** *គុ.* ទីទៃពីស្រាល គឺមានទម្ងន់ :

❖ អង្ករមួយបាវនេះធ្ងន់ណាស់ ខ្ញុំលីមិនរួចទេ។

❀ ជ្រុល, ដាបខ្លាំង :

❖ ជំងឺធ្ងន់

❖ របួសធ្ងន់។

❀ យូរ, ក្របានសម្រេចផល :

✈ **ស្រូវធ្ងន់** : ស្រូវដែលធ្វើយូរខែទើបបានផ្លែទុំ។

❀ ថ្លង់, ស្តាប់មិនសូវឮ :

❖ ធ្ងន់ត្រចៀក។

❀ មានអំណត់, ដែលស៊ូទ្រាំអត់ធ្មត់មិនងាយខឹងច្រឡោតផ្តេសផ្តាស :

❖ មនុស្សនេះមានចិត្តធ្ងន់ណាស់...។

**ធ្ងន់ធ្ងរ** *គុ.* ដែលមានចិត្តធ្ងន់, ដែលចេះអត់ចេះទ្រាំ, ដែលមានអំណត់, ដែលប៉ិនអត់ប៉ិនទ្រាំ :

❖ ចិត្តធ្ងន់ធ្ងរ

❖ មនុស្សធ្ងន់ធ្ងរ។

❀ ពាក្យ ធ្ងន់ធ្ងរ និយាយចំពោះតែចិត្តអធ្យាស្រ័យប៉ុណ្ណោះ ក្រៅពីនេះពាក្យដែលផ្សំជាមួយនឹង ធ្ងន់ នេះមានច្រើនត្រូវផ្សំតាមគួរដល់ដំណើរសេចក្តី។

**បណ្តា** *អា.និ.* ជំនុំ, អស់ទាំង, អំបាល។

❀ ពាក្យសម្រាប់និយាយដករំលែកចំនួននីមួយអំពីចំនួនច្រើនឱ្យដាច់ដោយឡែកផ្សេង :

❖ បណ្តាមនុស្សទាំង៣០នាក់នោះ មានតែមនុស្ស៥នាក់ទេដែលចេះសរសេរកើត។

❀ *និ.* អស់ទាំង, អំបាលម៉ាន :

❖ បណ្តាជន

❖ បណ្តារាស្ត្រ

❖ បណ្ដាកម្មករទាំងឡាយ ។

**បេសកកម្ម** *ន.* អំពើរបស់ជនអ្នកប្រើឬកិច្ចការរបស់ជនអ្នកចាត់ការបញ្ជូន។

🌹 សព្វថ្ងៃពាក្យនេះប្រើសំដៅយកអំណាចឬសិទ្ធិដែលប្រគល់ឱ្យដល់ប្រតិភូដើម្បីទៅបំពេញកិច្ចការអ្វីមួយនៅទីដទៃ; មុខការងារមានកំណត់ជាក់ប្រាកដថា ធ្វើយ៉ាងនេះឬធ្វើយ៉ាងនោះដែលរដ្ឋាភិបាលបានប្រគល់ឱ្យដល់ភ្នាក់ងាររាជការពិសេសដើម្បីធ្វើឱ្យបានសម្រេចមួយដងមួយគ្រា :

❖ បេសកកម្មខាងផ្លូវទូត

❖ បេសកកម្មនៃការចរចាអំពីសេដ្ឋកិច្ច។

🌹 ពាក្យនេះធ្លាប់បានប្រើមកជាយូរដែរហើយ, តែបើគិតដល់ន័យត្រង់ៗរបស់ពាក្យឃើញថា ដូចជាមិនសូវសម, បើប្រើជា "បេសិតកម្ម" ដូចជាគួរជាង ព្រោះមានន័យថា "អំពើរបស់ជនដែលត្រូវគេប្រើឬកិច្ចការរបស់ជនអ្នកទទួលបម្រើ"។

**បេសកជន** *ន.* ជនអ្នកប្រើ, ជនអ្នកបញ្ជូន។

🌹 ជនដែលទទួលភារៈទៅបំពេញបេសកកម្ម, ភ្នាក់ងារដែលគេចាត់ប្រើឱ្យទៅបំពេញបេសកកម្មអ្វីនីមួយនៅទីដទៃ, បើប្រើជា "បេសិតជន" គួរជាង។

**បំណាច** *ន.* សេចក្ដីប៉ង :

↳ **មានបំណាង** (កុំប្រើថា សេចក្ដីបំណាច ព្រោះពាក្យនេះជា នាមនាម

ប្រាប់ សេចក្តីប៉ង ស្រេចហើយ; បើចង់ប្រើពាក្យថា សេចក្តី ត្រូវថា មានសេចក្តីប៉ង ក៏គឺ មានបំណង ហ្នឹងឯង)។

➢ **មានបំណង** កុំប្រើថា មានការបំណង ដូច្នេះឡើយ។

➢ **មានបំណង** កុំប្រើថា មានក្តីបំណង ដូច្នេះឡើយ។

➢ **មានបំណង** កុំប្រើថា មានសេចក្តីបំណង ដូច្នេះឡើយ។

➢ **អស់បំណង** កុំប្រើថា អស់ការបំណង ដូច្នេះឡើយ។

➢ **អស់បំណង** កុំប្រើថា អស់ក្តីបំណង ដូច្នេះឡើយ។

➢ **អស់បំណង** កុំប្រើថា អស់សេចក្តីបំណង ដូច្នេះឡើយ។

❖ សមដូចបំណង

❖ មានបំណងនឹងទៅ

❖ បានសម្រេចតាមបំណង។

**ប្រព្រឹត្តិ** *ន.* ការធ្វើតាម, ការកាន់វត្តប្រតិបត្តិ; ដំណឹង; ហេតុ, ដើមហេតុ; រឿងរ៉ាវ; ពង្សាវតា :

❖ ការប្រព្រឹត្តិ

❖ សេចក្តីប្រព្រឹត្តិ។

📖 **ប្រព្រឹត្តិ** នេះជានាមសព្ទចេញពីកិរិយាសព្ទថា ប្រព្រឹត្ត ដោយផ្សំជាមួយនឹង ឥ-បច្ច័យ តម្រួតគ្នាជា ត្តិ (ជា ប្រព្រឹត្តិ) មានលក្ខណៈការដូចជា បញ្ញត្ត *កិ.*, បញ្ញត្តិ *ន.* នោះដែរ :

❖ រាជរដ្ឋាភិបាលបញ្ញត្តហើយថា...

❖ មានបញ្ញត្តិរបស់រាជរដ្ឋាភិបាលថា...

❖ មិនមានបង្គាប់ឱ្យប្រើពាក្យ ការ, ក្តី, ដំណើរ, សេចក្តី ផ្សំជាមួយផង ជាសេចក្តីបញ្ញត្តិទេ ពីព្រោះ បញ្ញត្តិ ជានាមសព្ទចេញពីកិរិយាសព្ទថា បញ្ញត្ត (ឱ្យជានាមសព្ទថា បញ្ញត្តិ ស្រេចទៅហើយ); គួរតែប្រើ ប្រព្រឹត្តិ នេះឱ្យដូច បញ្ញត្តិនោះដែរ គឺប្រើថា :

❖ អ្នកនុះមានប្រព្រឹត្តិត្រឹមត្រូវណាស់

❖ ប្រព្រឹត្តិរបស់គេជាទិដ្ឋានុគតិគួរអ្នកផងយកតម្រាប់តាម។

| | | | |
|---|---|---|---|
| **ការប្រព្រឹត្ត** | កុំប្រើថា | ការប្រព្រឹត្តិ | ដូច្នេះឡើយ។ |
| **ក្តីប្រព្រឹត្ត** | កុំប្រើថា | ក្តីប្រព្រឹត្តិ | ដូច្នេះឡើយ។ |
| **ដំណើរប្រព្រឹត្ត** | កុំប្រើថា | ដំណើរប្រព្រឹត្តិ | ដូច្នេះឡើយ។ |
| **សេចក្តីប្រព្រឹត្ត** | កុំប្រើថា | សេចក្តីប្រព្រឹត្តិ | ដូច្នេះឡើយ។ |

📖 ប៉ុន្តែដោយមានទម្លាប់ប្រើផ្សំជាមួយនឹង ការ, ក្តី, ដំណើរ, សេចក្តី ផងដូច្នេះយូរណាស់ទៅហើយ, ទោះបីខុសពីបែបវេយ្យាករណ៍ខ្មែរយ៉ាងនេះក៏ដោយ អ្នកអក្សរសាស្ត្រក៏គួរពិចារណាឱ្យហ្មត់ចត់ល្អិតល្អចុះ។

**ប្រសាសន៍** *ន.* ពាក្យបង្គាប់, ពាក្យផ្តាំផ្ញើ, បណ្តាំ។

❀ ខ្មែរយើងប្រើចំពោះតែពាក្យសម្តីរបស់ឥស្សរជនក្រៅពីក្សត្រ :

**ទទួលប្រសាសន៍លោក** គឺ ទទួលពាក្យលោក

**លោកមានប្រសាសន៍** គឺ លោកនិយាយ។

ពាក្យ ប្រសាសន៍ សម្រាប់ប្រើចំពោះ ឥស្សរជន ជា គ្រហស្ថ។

**ប្រសូត១** *កិ.* សម្រាលកូន។

ខ្មែរយើងប្រើជា *វេ.* សម្រាប់ហៅ ស្ត្រីជាឥស្សរ្រត្រ សម្រាលកូន។

**ប្រសូត២** *ន.* ដំណើរសម្រាលកូន, ការសម្រាលកូន។

ខ្មែរយើងប្រើជា *វេ.* សម្រាប់ហៅ ស្ត្រីជាឥស្សរ្រត្រ សម្រាលកូន។

**ប្រាក់១** *ន.* រ៉ែឬរតនវត្ថុមួយប្រភេទមានសម្បុរ-ស សាច់រឹង មានតម្លៃរង បន្ទាប់ពីមាសមក, ជារបស់សម្រាប់ចាយនិងប្រកបការបានច្រើនយ៉ាង... :

- ប្រាក់ដួង
- ប្រាក់សុទ្ធ
- ប្រាក់ណែន
- ប្រាក់មួយរៀល។

**ផ្តិលប្រាក់** : ផ្តិលដែលធ្វើដោយប្រាក់។

**ប្រអប់ប្រាក់** : ប្រអប់ដែលធ្វើដោយប្រាក់។

**ប្រាក់២** *ន.* ក្រដាសចេញឱ្យប្រើសម្រាប់ចាយជំនួសប្រាក់ក៏ហៅថា ប្រាក់ ដែរ :

- ប្រាក់មួយរៀល
- ប្រាក់ប្រាំរៀល (គួរហៅ ធនបត្រ ឬ ហិរញ្ញបត្រ វិញ) ...។

**ពណ៌** *ន.* (*សំ. វណ៌; បា. វណ្ណ* **"សម្បុរ, ពូក, ថ្នាក់ត្រកូល, ភេទ, ពាក្យសរសើរ, គុណដែលគួរសរសើរ, អក្សរ, ..."**) សម្បុរ :

- ពណ៌ស
- ពណ៌ខ្មៅ
- ពណ៌លឿង
- ពណ៌ប្រផេះ
- ពណ៌ក្រហម...។

📖 ពាក្យ ពណ៌ នេះខ្មែរយើងប្រើចំពោះតែសម្បុរនៃ វត្ថុ ផ្សេងៗមានសំពត់ជាដើម បើចំពោះ មនុស្ស ឬ សត្វ ប្រើពាក្យថា សម្បុរ, គេនិយាយថា :

- គោសម្បុរត្នោត
- មនុស្សសម្បុរ-ស...។

**ពន្លឹក** *គុ.* ដែលគួរភ្លឹក, ដែលគួរស្ញើម :

- កាចពន្លឹក
- ភ័យពន្លឹក
- ភ័យដ៏ពន្លឹក
- ភ្លើងឆេះផ្ទះពេញទាំងភូមិជាអគ្គិភ័យដ៏ពន្លឹក។

📖 កុំច្រឡំប្រើពាក្យ ពន្លឹក នេះថា អរពន្លឹក, សប្បាយពន្លឹក ព្រោះពុំមែនជាហេតុគួរឱ្យ ភ្លឹក ឱ្យភ្លេច ឱ្យស្លន់ ភ័ន្តគំនិតទេ។

**ពួក ៩.** បន, ចំនួនគ្នាច្រើនដោយឡែកផ្សេងៗ, ចំនួនប្រជុំដោយក្រុម :

❖ កាន់ពួក

❖ នៅដោយពួក

❖ លើកគ្នាជាពួក។

**ពួកក្មេង** : បនក្មេង, ក្មេងទាំងឡាយ។

**ពួកម៉ាក** : គូកន, មិត្ត, សំឡាញ់។

**ពុំ ៩.** មិន, ឥត :

❖ ពុំសូវល្អ

❖ ទៅពុំខាន

❖ ធ្វើពុំកើត

❖ ពុំប្រសើរ

❖ ពុំគាប់ចិត្ត

❖ ពុំយូរប៉ុន្មាន

❖ មានជាដរាបពុំដែលដាច់

❖ ធ្វើដូច្នេះទៀតពុំបានឡើយ...។

តាមទម្លាប់ប្រើ, បើ អ្នកតូច និយាយស្ដីក្នុងសំណាក់ ឥស្សរជន តែងប្រើពាក្យ ពុំ ជំនួសពាក្យ មិន ជាដរាប :

❖ ទូលព្រះបង្គំជាខ្ញុំពុំដែលបានឃើញ

❖ ខ្ញុំព្រះបាទម្ចាស់ពុំដែលបានទៅ

❖ ការនោះខ្ញុំបាទធ្វើពុំកើត

❖ សេចក្ដីគួរពុំគួរសូម...អភ័យទោស។

- **ពុំជា** : មិនល្អ, មានសៅហ្មង, ឆ្គាំឆ្គង; មានជំងឺ។
- **ពុំជាបើ** : មិនជាបើ។
- **ពុំជាបើបី** : មិនជាបើបី។
- **ពុំជាបីបើ** : មិនជាបីបើ។
- **ពុំសមបើ** : មិនសមបើ។
- **ពុំសមបីបើ** : មិនសមបីបើ។
- **ពុំលង់ឡើយ** : មិនយូរឡើយ...។

**ពុំនោះ** ឬ **ពុំនោះសោត** *និ.* មួយទៀត, មួយវិញទៀត, មួយវិញសោត, បើមិនដូច្នោះ។

❀ ពាក្យនិបាតជាសន្ធានសម្រាប់ប្រើតសង្កាត់សេចក្ដីបន្ទាប់អំពីពាក្យ ឬ, ឬក៏, ឬថា។

☞ ប្រើរៀងបន្តគ្នាតាមលំដាប់មុខក្រោយ គឺពាក្យ :

- **ឬ** ត្រូវរៀងមុន
- **ឬក៏** ត្រូវរៀងត្រង់ទី២
- **ពុំនោះ** ត្រូវរៀងត្រង់ទី៣

↳ **ពុំនោះសោត** គ្រូវរៀនត្រង់ទី៤ :

❖ ត្រូវចាត់បម្រើឱ្យទៅប្រាប់ ឬផ្ដាំផ្ញើនឹងមនុស្សអ្នកទៅមក ឬក៏សរសេរសំបុត្រឱ្យបម្រើយកទៅ ពុំនោះផ្ញើនឹងគេអ្នកទៅមក ពុំនោះសោតបិទតែមប្រើផ្ញើតាមប្រៃសណីយ៍ក៏បាន។

**ព្រហ្មចារី** *ន.* (*ឆា.*) អ្នកប្រព្រឹត្តព្រហ្មចារ្យ។

❀ ពាក្យនេះតាមលទ្ធិព្រាហ្មណ៍សំដៅយកអ្នកដែលកំពុងហាត់រៀនវេទ ឬអ្នកដែលកំពុងសិក្សាលទ្ធិសាសនា ឬក៏កំពុងប្រព្រឹត្តធម៌តាមបែបសាសនា។

❀ តាមលទ្ធិពុទ្ធសាសនា សំដៅយកអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ណាមួយ ឬសំដៅចំពោះតែអ្នកដែលវៀរមេថុនធម្មដោយដាច់ខាត យ៉ាងដូចបព្វជិតមានភិក្ខុ, សាមណេរជាដើម។

❀ តាមលទ្ធិបុរាណសំដៅយកកុមារឬកុមារីដែលនៅលីវសុទ្ធសាធ។

❀ ខាងលទ្ធិខ្មែរដែលប្រើតាមទម្លាប់ច្រើនតែសំដៅយក កុមារី ជំទង់ហៅថា ស្រ្តីព្រហ្មចារី។

📖 តែបើតាមបែបត្រឹមត្រូវ ព្រហ្មចារី សម្រាប់ហៅ បុរស, ឯ ស្រ្តី ត្រូវហៅ ព្រហ្មចារិនី។

**មិន** *និ.* ពាក្យនិបាតជាបដិសេធសម្រាប់និយាយនាំមុខ *កិ., គុ.* ឬ *កិ.វិ.* មានសេចក្ដីថា “ពុំ, ឥត” :

❖ មិនកើត

❖ មិនឃើញ

❖ មិនឆាប់

❖ មិនដឹង

❖ មិនតូច

❖ មិនធំ

❖ មិនយឺត

❖ មិនយូរ

❖ មិនលឿន

❖ មិនល្អ

❖ មិនអាក្រក់...។

**មិនជា** : ពុំជា។

**មិនជាបើ** : ពុំជាបើ។

**មិនសមបើ** : ពុំសមបើ។

**មិនសមបីបើ** : ពុំសមបីបើ។

ក្នុងសង្កាត់សេចក្ដីជាបដិសេធនីមួយ, កាលណាបើប្រើពាក្យ មិន, ពុំ ឬ ឥត នេះជាខាងដើមហើយនឹងប្រើពាក្យថា ក៏ទេ នេះជាខាងចុងផងពុំបានឡើយ, ដូចជា :

❖ ខ្ញុំពុំដែលបានឮក៏ទេ

❖ ខ្ញុំឥតដែលបានដឹងក៏ទេ

❖ ខ្ញុំមិនដែលបានឃើញក៏ទេ។

🌹 ប្រើយ៉ាងនេះពេញជាខុសទាំងស្រុង ព្រោះត្រឡប់ក្លាយសេចក្ដីមិនមែនជាបដិសេធទៅវិញ, ត្រូវប្រើពាក្យ ទេ, ឡើយ ឬ សោះ នេះវិញ :

❖ ខ្ញុំមិនដែលបានឃើញទេ

❖ ខ្ញុំពុំដែលបានឮឡើយ

❖ ខ្ញុំឥតដែលបានដឹងសោះ។

➥ ឯពាក្យ ក៏ទេ នេះជា សព្ទបដិសេធ សម្រាប់ប្រើបានតែជាមួយនឹងពាក្យថា នឹង រៀងនៅជាខាងដើម, ដូចជា :

❖ ខ្ញុំនឹងដែលបានឃើញក៏ទេ

❖ ខ្ញុំនឹងដែលបានឮក៏ទេដែរ

❖ ខ្ញុំនឹងដែលបានដឹងក៏ទេសោះ

☞ គឺ ខ្ញុំមិនដែលបានឃើញទេ...។

**ម៉ឺន** ឬ **ហ្មឺន** *ឧ.សំ.* ចំនួនសំខ្យាដប់ពាន់ (១០ ០០០)។

🌹 *១.* បណ្ដាសក្ដិមន្ត្រីមុនទីឃុន រាប់តាមលំដាប់បណ្ដាសក្តិពីថ្នាក់ក្រោមបំផុតឡើងរៀងទៅថ្នាក់លើថា :

❖ ម៉ឺន ឬ ហ្មឺន

❖ ឃុន

❖ ហ្លួង

❖ ព្រះ

❖ ឧកញ៉ា។

☞ តាមបវេណីរាជ្យក្នុងកម្ពុជរដ្ឋពីកាលជាន់បុរាណ, កូនប្រុសរបស់សេនាបតីឬរបស់ស្តេចត្រាញ់ត្រូវហៅ ម៉ឺន តាំងពីនៅជាកុមារតូចពុំចាំបាច់តាំងឡើយ (បើកូនស្រីហៅ អ្នកនាង)។

**ម៉ែត្រ ៩** ឈ្មោះរង្វាស់បារាំងប្រវែងដប់ដេស៊ីម៉ែត្រឬមួយរយសង់ទីម៉ែត្រឬក៏មួយពាន់មិល្លីម៉ែត្រ។

❀ ជារង្វាស់ដែលក្នុងសម័យសព្វថ្ងៃនេះខ្មែរចេះប្រើពេញទាំងកម្ពុជរដ្ឋ។

❀ បើធៀបនឹងរង្វាស់របស់ខ្មែរពីដើមត្រូវគ្នានឹងប្រវែងពីរហត្ថជាងឈើដែលហៅថា ហត្ថខ្នាត (ពីរហត្ថខ្នាត)។

❀ ធៀបនឹងហត្ថមនុស្សប្រក្រតី សព្វថ្ងៃនេះច្រើនតែពីរហត្ថមួយទះឬលើសខ្វះពីនោះបន្តិចបន្តួច (ម៉ែត្រ សរសេរកាត់ថា ម. )។

➢ **ដេស៊ីម៉ែត្រ** : ប្រវែងដប់សង់ទីម៉ែត្រ (ដ.ម.)។

➢ **សង់ទីម៉ែត្រ** : ចំនួនឬប្រវែងមួយរយភាគដែលចែកឬដែលបែងចេញពីក្នុងមួយម៉ែត្រ (ស.ម.) ។

➢ **មិល្លីម៉ែត្រ** : ចំនួនឬប្រវែងមួយពាន់ភាគដែលចែកឬដែលបែងចេញពីក្នុងមួយម៉ែត្រ (ម.ម.) ។

✎ **ដេកាម៉ែត្រ** : ចម្ងាយឬប្រវែងដប់ម៉ែត្រ (ដា.ម.)។

✎ **ហិកតូម៉ែត្រ** : ចម្ងាយឬប្រវែងមួយរយម៉ែត្រ (ហ.ម.)។

✎ **គីឡូម៉ែត្រ** : ចម្ងាយឬប្រវែងមួយពាន់ម៉ែត្រ (គ.ម.)។

✎ **ម៉ែត្រការ៉េ** : មានទំហំទីបួនជ្រុងស្មើភាគ, ម៉ែត្រទ្វេគុណ (ម.២); កុំប្រើពាក្យ ម៉ែត្រក្រឡា ព្រោះជាពាក្យគន្លាស់ពុំសមរម្យ, ត្រូវប្រើពាក្យ ម៉ែត្រទ្វេគុណ ឬ ម៉ែត្រការ៉េ (តាមបារាំង) វិញក៏បាន។

✎ **ម៉ែត្រគុប** : មានកម្ពស់មួយម៉ែត្របួនជ្រុងស្មើភាគ, ម៉ែត្រត្រីគុណ (ម.៣)...។

**ម្ចាស់** *ន.* អ្នកមានអំណាចកាន់កាប់អ្វីៗដែលជារបស់ខ្លួន, ឥស្សរជន :

- ម្ចាស់ផ្ទះ
- ម្ចាស់ទ្រព្យ
- ម្ចាស់បំណុល...។

✎ **ម្ចាស់ខ្លួន** : សាមីខ្លួន, ខ្លួនរបស់ឯងឬខ្លួនរបស់គេ។

✎ **ម្ចាស់ជីវិត** : ម្ចាស់ជីវិតលើត្បូង, ម្ចាស់ផែនដី, ព្រះរាជា (ក្សត្រទ្រង់រាជ្យ), ត្រូវប្រើពាក្យថា ព្រះករុណា ផ្សំខាងដើមជាដរាបគឺ :

- ព្រះករុណាជាម្ចាស់ជីវិត, ... (បុរាណប្រើជា អម្ចាស់)។

✎ **ព្រះអង្គម្ចាស់** : ព្រះរាជបុត្រ ឬ ព្រះរាជបុត្រី នៃ ក្សត្រទ្រង់រាជ្យ ឬ ក្សត្រឧភយោរាជ, ក្សត្រឧបរាជ, ក្សត្រឧបយុវរាជ, ឬក៏ បុត្រាបុត្រី ដែល

កើតអំពី ព្រះរាជបុត្រ រួមនឹង ព្រះរាជបុត្រី។

✍ **អ្នកអង្គម្ចាស់** : បុត្រាបុត្រី ដែលមានព្រះអង្គម្ចាស់ជា បិតា ឬ បុត្រាបុត្រី ដែលកើតអំពី អ្នកអង្គម្ចាស់ រួមគ្នាជា មាតាបិតា (ពាក្យធម្មតាដែលប្រើជាប្រក្រតីថា ម្ចាស់) ...។

**ម្នាក់** *គុ.* មួយនាក់ :

❖ មនុស្សម្នាក់

❖ គ្នាពីរនាក់ ក្មេងម្នាក់ ចាស់ម្នាក់។

✍ **ម្នាក់ទៀត** : មួយនាក់ទៀត, អ្នកមួយទៀត។

✍ **ម្នាក់ឯង** : ម្នាក់គត់...។

**យើង** *ឧ.ស.* ខ្ញុំទាំងឡាយ, ពួកខ្ញុំ :

❖ យើងត្រូវទៅ។

➢ សម្រាប់និយាយក្រាបទូលក្សត្រ *ព.ឧ.* ថា :

✍ យើងខ្ញុំព្រះអង្គ; *ព.ស.ស.* ថា ទូលព្រះបង្គំជាខ្ញុំទាំងឡាយ...។

➢ សម្រាប់និយាយនឹងសេនាបតីថា :

✍ យើងខ្ញុំព្រះបាទម្ចាស់។

➢ សម្រាប់និយាយនឹងមន្ត្រីសក្តិធំចុះពីសេនាបតីមកថា :

✍ យើងខ្ញុំព្រះបាទ។

➢ សម្រាប់និយាយនឹងព្រះភិក្ខុសង្ឃថា :

📜 យើងខ្ញុំព្រះករុណា។

↳ សម្រាប់និយាយនឹងមន្ត្រីសក្តិតូចឬនឹងរាស្ត្រដោយគោរពថា :

📜 យើងខ្ញុំ។

↳ បើស្ត្រីប្រើតាមលំដាប់ជាន់ថ្នាក់ខ្ពស់ទាបមានត្រឹមតែ :

📜 យើងខ្ញុំម្ចាស់, យើងខ្ញុំ, យើង ប៉ុណ្ណោះ។

**រលែក** *កិ.* ចែកជាភាគ, បែកជាភាគ, ញែកជាភាគ :

❖ ប្រមូលមនុស្សមិនឱ្យរលែកគ្នា។

**ចែករលែក** : ចែកបែងឱ្យជាភាគស្មើគ្នាឬតិចច្រើនជាងគ្នា ប៉ុន្តែឱ្យបានគ្រប់គ្នា។

**ដើររលែកគ្នា** : ដើរបែកទាសចេញពីគ្នា។

**រាស្ត្រ** *ន.* ដែន, ប្រទេស; អ្នកនៅក្នុងដែន, ប្រជាជន។

📖 ខ្មែរប្រើពាក្យនេះសំដៅសេចក្តីថា "ប្រជាជនសម្រាប់ដែន (ក្រៅពីពួក ក្សត្រ និង នាហ្មឺន)" :

❖ ពួករាស្ត្រ

❖ កែនរាស្ត្រ។

**រាស្ត្រទាស** : រាស្ត្រជាខ្ញុំបម្រើគេ, បណ្តារាស្ត្រដែលទុកថាជាខ្ញុំម្ចាស់ផែនដី។

**រាស្ត្រប្រជា** : ពួកជនចំណុះដែន, ប្រជារាស្ត្រ។

- **ប្រជារាស្ត្រ** : ពួកជនចំណុះដែន, រាស្ត្រប្រជា។
- **បណ្តារាស្ត្រ** : រាស្ត្រទាំងឡាយ, រាស្ត្រគ្រប់គ្នា។
- **អាណាប្រជារាស្ត្រ** : ប្រជារាស្ត្រក្នុងអាណាចក្រនីមួយ។
- **អាណាប្រជានុរាស្ត្រ** : ប្រជារាស្ត្រធំតូចក្នុងអាណាចក្រនីមួយ។

**រូប ៩.** ធម្មជាតដែលប្រែប្រួលឬវិនាសដោយហេតុផ្សេងៗមានក្តៅនិងត្រជាក់ជាដើម, អ្វីៗដែលប្រាកដដល់ :

- ខ្លួន
- ខ្លួនប្រាណ
- ទ្រង់
- ទ្រង់ទ្រាយ
- ភ្លែក
- រាង
- លម្អ
- សណ្ឋាន
- អង្គ ... :

- រូបគេ
- រូបយើង
- រូបល្អ
- រូបអាក្រក់

❖ មនុស្សសត្វរាល់រូបសុទ្ធតែមិនទៀងដូចគ្នា។

ពាក្យ រូប សម្រាប់ប្រើជាចុងចំនួនរាប់បព្វជិតឱ្យដឹងថាប៉ុន្មាន :

❖ ភិក្ខុមួយរូប

❖ សាមណេរពីររូប

❖ តាបសមួយរូប

❖ បរិព្វាជកច្រើនរូប។

ពាក្យចុងចំនួនរាប់ មានទម្លាប់ឱ្យប្រើផ្សេងគ្នាតាមថ្នាក់បុគ្គល :

❖ ព្រះពុទ្ធ

❖ ព្រះបច្ចេកពុទ្ធ

❖ ព្រះអរហន្ត

❖ ពោធិសត្វ

❖ ព្រហ្ម

❖ ទេវតាសក្តិធំ

❖ ក្សត្រ។

បព្វជិតអ្នកធំត្រូវប្រើពាក្យថា អង្គ គឺប្រើថា :

❖ មួយអង្គ

❖ ពីរអង្គ

❖ ច្រើនអង្គ។

❀ បព្វជិតធម្មតាឬសាមណេរថា រូប គឺប្រើថា :

❖ មួយរូប

❖ ពីររូប

❖ ច្រើនរូប។

❀ គ្រហស្ថក្រៅពីក្សត្រថា នាក់ គឺប្រើថា :

❖ មួយនាក់

❖ ពីរនាក់

❖ បីនាក់

❖ ច្រើននាក់។

**រំលែក** *កិ.* ធ្វើឱ្យញែកចេញខ្លះ, បំបែកចេញខ្លះ, ធ្វើឱ្យរលស់ចេញខ្លះ, យកចេញខ្លះ, ចែកឱ្យខ្លះតាមការគួរ :

❖ រំលែកម្ហូបចែកគ្នា។

**ឬ** *និ.* ពាក្យនិបាតសម្រាប់និយាយដោយសេចក្ដីសង្ស័យ, មិនប្រាកដ, មិនដាច់ស្រេច, មិនអស់មិនហើយ :

❖ មិនមែនឬ?

❖ មានដែរឬ?

❖ មាសឬប្រាក់?

**ឬក៏** *និ.* ពុំនោះក៏ :

❖ ថ្ងៃនេះ ឬស្អែក ឬក៏ខានស្អែក។

✈ **ឬថា** *និ.* ពុំនោះថា :

❖ ថាឃើញ ឬឮ ឬថាមិនឃើញមិនឮទេ?។

✈ **ឬទេ** *និ.* ដែរទេ? :

❖ បានឬទេ?។

✈ **ឬ...ហ្ន៎?** *និ.* ដែរ...ហ្ន៎? ទេដឹងហ្ន៎?

❖ ប្រហែលជាមិនកើតទេឬហ្ន៎?។

✈ **ឬអ្វី?** *និ.* ឬដូចម្ដេច?, ឬម្ដេច? :

❖ មិនទៅទេឬអ្វី?...។

✈ **ឬអី?** *និ.* ឬដូចម្ដេច?, ឬម្ដេច? :

❖ មិនទៅទេឬអី?...។

**លក់១** *កិ.* ចំណាយទំនិញ, ឱ្យរបស់ទៅអ្នកទិញដោយយកថ្លៃ :

❖ លក់ទំនិញ។

❖ ត្រូវគេលក់៣០០០រៀល (*ពិន័យតាមច្បាប់បញ្ញត្តិ*)។

☆ **ការលក់១ *(ពាក្យច្បាប់)*** គឺជាកិច្ចសន្យាមួយដែលជនម្នាក់ហៅថា អ្នកលក់ត្រូវផ្ទេរកម្មសិទ្ធិនៃវត្ថុណាមួយឬសិទ្ធិណាមួយរបស់ខ្លួនឱ្យទៅជនម្នាក់ទៀតហៅថា អ្នកទិញ ដែលជាអ្នកត្រូវចេញថ្លៃជាប្រាក់តាមតម្លៃនៃវត្ថុនោះឱ្យអ្នកលក់វិញ។

☆ **ការលក់២** *(ពាក្យច្បាប់)* គឺជាកិច្ចសន្យាដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយ ឬសិទ្ធិណាមួយឱ្យទៅបុគ្គលម្នាក់ទៀតដែលមានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ថ្លៃវត្ថុឬសិទ្ធិនោះមកវិញ។

**លក់ខ្លួន** *កិ.* ចំណាយខ្លួនឱ្យជាអ្នកនៅបម្រើគេ។

**លក់ជឿ** *កិ.* លក់ពុំទាន់យកថ្លៃដល់ដៃភ្លាមនៅឡើយដោយជឿថាអ្នកទិញនឹងចេញតម្លៃឱ្យពុំខាន។

**លក់ដូរ** *កិ.* លក់ខ្លះដូរខ្លះ គឺលក់របស់របរប៉ិចរប៉ិវាយរង។

**លក់ដុំ** *កិ.* លក់ទាំងដុំៗ ទីទៃពីលក់រាយ។

**លក់រាយ** *កិ.* លក់រាយៗតាមតែគេទិញអ្វីៗ ប៉ុន្មានៗក៏ដោយទីទៃពីលក់ដុំ។

**លក់ល្ពៃ** *កិ.* ពិន័យលក់ទ្វេគុណ (ក្លាយមកពីពាក្យថា លក់ពិន័យ ឬ ពិន័យលក់)។

📖 ពាក្យ លក់ នេះបើរបស់ដែលទាក់ទងខាងព្រះពុទ្ធសាសនាត្រូវថា ជាវ, អ្នកលក់និងអ្នកទិញត្រូវថា ជាវ ដូចគ្នា :

- ជាវគម្ពីរ
- ជាវបាត្រ
- ជាវត្រៃចីវរ
- ជាវសៀវភៅធម៌...។

🕮 បើបព្វជិតនិងអ្នកលក់ត្រូវថា ពិចារណា ដូចជាថា :

❖ លោកគ្រូឱ្យគេពិចារណាតែបាត្រមួយទេឬឱ្យគេពិចារណាគ្រឿងបរិក្ខារអ្វីទៀតដែរ?...។

**លក់២** *កិ.* ដេកស៊ប់ស្ងាត់អារម្មណ៍មិនដឹងខ្លួន (លក់មួយល្បក់)។

**លក់លង់** *កិ.* លក់ជ្រុលដំណេក។

**លក់លន់** *កិ.* លក់ហួសប្រមាណ, លក់ជ្រៅមិនងាយភ្ញាក់, លន់លក់។

**លន់លក់** *កិ.* លក់ហួសប្រមាណ, លក់ជ្រៅមិនងាយភ្ញាក់, លក់លន់។

*ពាក្យកាព្យ*

លក់លន់លង់ជ្រៅ ទោះខ្លួនដេកនៅ ក្នុងគ្រឹហាឋាន
មានចោរកំណាច អាចគាស់ទ្វារបាន លួចទ្រព្យហើយច្រាន
ទ្វារបិទដូចដើម។

**លក់ស្វា** *កិ.* លក់ពភ្លឹមពភ្លែត គឺស្ទើរលក់ស្ទើរភ្ញាក់ (បាលីហៅថា **កបិមិទ្ធ** “*លក់ស្វា*” ការយល់សប្តឃើញអ្វីៗ ទោះពិតក្តី មិនពិតក្តី ឃើញត្រង់ស្របក់នេះឯង ពុំមែនពេញជាលក់ ពុំមែនពេញជាភ្ញាក់ គឺត្រង់ចន្លោះលក់និងភ្ញាក់; *ព.ខ.ព.*)។

*(ព.ប្រ.)* ដេកលក់ឬលក់ជានិច្ច ត្រាំគំនិតនៅក្នុងដំណើរមិនយល់ការខុសត្រូវឬប្រហែសធ្វេសជានិច្ច។

**លម្អៀង** *កិ.* ធ្វើឱ្យល្អៀង, ឱ្យផ្អៀងទៅរកម្ខាងជាងម្ខាង (ចំពោះតែផ្លូវចិត្ត) :

❖ លម្អៀងចិត្ត

❖ លម្អៀងសេចក្ដី

❖ ចៅក្រមកាត់ក្ដីលម្អៀង។

**លុយ** *ន.* លោហៈសណ្ឋានមូលតូចសំប៉ែតមានរូបភាពឬត្រានឹងអក្សរជាសម្គាល់, សម្រាប់ប្រើចាយជាជំនួសប្រាក់។

❀ ក្នុងកម្ពុជរដ្ឋសម័យពីដើមមានតម្លៃ ពីរសេន និង មួយសេន, សព្វថ្ងៃនេះមានតម្លៃ មួយសេន និង កន្លះសេន; ហៅក្លាយមកពីពាក្យថា លួី (Louis) ដែលជាព្រះនាមព្រះមហាក្សត្រប្រទេសបារាំងក្នុងសម័យពីដើម...។

❀ ពាក្យសាមញ្ញហៅ ប្រាក់ ដែលសម្រាប់ចាយវាយក្នុងកម្ពុជរដ្ឋសព្វថ្ងៃថា :

❖ គេមានលុយច្រើន

❖ អស់លុយចាយរលីង។

🕮 ចាស់ទុំលោកថាកុំហៅ ប្រាក់ពាន់ម៉ឺន ថា លុយ ពីព្រោះ លុយ មានតម្លៃតូចជាង ប្រាក់ គឺកុំនិយាយបន្ទាបវត្ថុមានតម្លៃឱ្យថយថោក (ចាស់ៗថាមាត់ស៊ីអំបិលព្រហក់)។

**លោក១** *ន.* សភាវធម៌ដែលតែងកើតតែងវិនាសរឿយៗឬដែលបាត់ៗ ឃើញៗ គឺដែលកើតមានហើយបាត់ បាត់ហើយមានឡើងវិញតាមកាលសម័យ;

បើនិយាយដោយការរៀបរាប់ :

❖ ដី

❖ ទឹក

❖ ភ្លើង

❖ ខ្យល់

❖ អាកាស

❖ ឋានសួគ៌

❖ ឋាននរក

❖ ឋានព្រហ្ម

❖ ឋានប្រេត

❖ ឋានមនុស្ស

❖ មនុស្សសត្វទូទៅទាំងអស់...។

ប្រើភ្ជាប់ជាមួយនឹងសព្ទដទៃបានតាមគួរដល់ការប្រកប។

ប្រើរៀងខាងដើម *ន.ឲ.* លោក:, ដូចជា :

❖ លោកធម៌

❖ លោកបាល

❖ លោកសន្និវាស...។

❀ បើរៀងពីខាងចុង *អ.ឧ.* លោក, ដូចជា :

❖ ទេវលោក

❖ ព្រហ្មលោក

❖ មនុស្សលោក...។

➥ **លោកកថា** : រឿងរ៉ាវសម្រាប់លោក, រឿងព្រេង។

➥ **លោកកាណ្ឌ** : មនុស្សដែលប្រព្រឹត្តអំពើអាក្រក់ក្រៃពេកទុកដូចជាដង្គត់ឬដូចជាចម្រូងក្នុងលោក, លោកស្ថាណុ។

➥ **លោកគតិ** : ដំណើររបស់លោក គឺកិច្ចការរបស់មនុស្សឬសត្វ។

➥ **លោកគុរុ** : លោកគុរុ, អ្នកធ្ងន់ក្នុងលោកឬដែលជាគ្រូរបស់សត្វលោកគឺ ព្រះសព្វញ្ញុពុទ្ធ; តាមលទ្ធិព្រាហ្មណ៍ថា ព្រះព្រហ្ម។

➥ **លោកចក្ខុ** : លោកចក្សុ, ភ្នែករបស់លោកគឺ ព្រះអាទិត្យ។

➥ **លោកចក្សុ** : លោកចក្ខុ, ភ្នែករបស់លោកគឺ ព្រះអាទិត្យ។

➥ **លោកចិន្តា** : សេចក្ដីរិះគិតអំពីលោក គឺការរិះគិតរកហេតុរកដំណើរក្នុងលោក។

➥ **លោកជនក** : លោកបិតា, បិតារបស់លោកគឺ ព្រះសិវៈ ឬ វិស្ណុ (តាមលទ្ធិព្រាហ្មណ៍)។

➥ **លោកបិតា** : លោកជនក, បិតារបស់លោកគឺ ព្រះសិវៈ ឬ វិស្ណុ (តាមលទ្ធិព្រាហ្មណ៍)។

➢ **លោកជននី** : លោកមាតា, មាតារបស់លោកគឺនាង ឧមា ឬ លក្ស្មី (តាមលទ្ធិព្រាហ្មណ៍)។

➢ **លោកជេដ្ឋ** : លោកជេស្ឋ, លោកសេដ្ឋ, អ្នកប្រសើរឬអ្នកចម្បងជាងសត្វលោកគឺ ព្រះសម្មាសម្ពុទ្ធ; តាមលទ្ធិព្រាហ្មណ៍ថា ព្រះព្រហ្ម។

➢ **លោកត្ថចរិយា** : ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់លោក (ចរិយារបស់ពុទ្ធាទិបណ្ឌិត)។

➢ **លោកត្រ័យ** : លោកបី គឺមនុស្សលោក, ទេវលោក, ព្រហ្មលោក; មានន័យដទៃផ្សេងថា មេឃ ឬ ឋានសួគ៌, ផែនដី, ឱកាសកណ្តាល (ចន្លោះមេឃនិងដី) ឬ បាតាល។

➢ **លោកធម្មតា** : ធម្មតារបស់លោក គឺការមិនទៀងរបស់លោក។

➢ **លោកធម៌** : ធម៌សម្រាប់លោក គឺអាការៈ, សណ្តាប់ធ្នាប់ឬធម្មតារបស់សត្វលោក; តាមពុទ្ធសាសនា ថាមាន៨យ៉ាង :

**១- លាភៈ** : ការបាន

**២- អលាភៈ** : ការខានបានឬខាតបង់

**៣- យសៈ** : ការមានយសសក្តិ

**៤- អយសៈ** : ការមិនមានយសសក្តិឬការថ្លោះធ្លាក់យសសក្តិ

**៥- បសំសា** : ការសរសើរ

**៦- និន្ទា** : ការតិះដៀល

**៧- សុខៈ** : ការបានសុខ

**៨- ទុក្ខៈ** : ការបានទុក្ខ។

➷ **លោកធាតា** : លោកធាត្ញ, អ្នកបង្កើតលោក គឺ ព្រះព្រហ្ម ឬ ព្រះសិវៈ (តាមលទ្ធិព្រាហ្មណ៍)។

➷ **លោកធាតុ** : លោកធាតា, អ្នកបង្កើតលោក គឺ ព្រះព្រហ្ម ឬ ព្រះសិវៈ (តាមលទ្ធិព្រាហ្មណ៍)។

➷ **លោកធាតុ** : ចក្រវាល, ទំហំលោកក្នុងមណ្ឌលចក្រវាលមួយៗ។

➷ **លោកនាថ** : អ្នកដែលជាពំនាក់សត្វលោកគឺ ព្រះសម្មាសម្ពុទ្ធ; តាមលទ្ធិព្រាហ្មណ៍ថា ព្រះព្រហ្ម, ព្រះសិវៈ, ព្រះនារាយណ៍។

➷ **លោកនាយក** : អ្នកដឹកនាំសត្វលោក (ព្រះសព្វញ្ញុពុទ្ធ)។

➷ **លោកនិន្ទាទ** : ស្វរសព្ទគឹកកងក្នុងលោក; ដំណើរល្បីលេចឮសាយសុសក្នុងលោក។

➷ **លោកនិយម** : ធម្មតារបស់លោក។

➷ **លោកនិស្សិត** : ដែលអាស្រ័យនៅក្នុងលោក, មនុស្សឬអ្វីៗទាំងអស់ដែលមាននៅក្នុងលោក។

➷ **លោកន្តគូ** : អ្នកដល់នូវទីបំផុតលោក (ព្រះខីណាស្រព)។

➷ **លោកន្តទស្សី** : អ្នកឃើញទីបំផុតលោក គឺអ្នកឃើញព្រះនិព្វាន (ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះអរហន្ត)។

↳ **លោកន្តរ** : ទីឬប្រទេសជាចន្លោះលោក; ឈ្មោះនរកនៅត្រង់ចន្លោះលោក (ហៅ លោកន្តរនរក ក៏បាន)។

↳ **លោកបថ** : លោកបទ, ផ្លូវលោក គឺសណ្ដាប់ធ្នាប់, បែបបទ, ទំនៀមរបស់សត្វលោក; ទំនៀមស្រុកទេស។

↳ **លោកបទ** : លោកបថ, ផ្លូវលោក គឺសណ្ដាប់ធ្នាប់, បែបបទ, ទំនៀមរបស់សត្វលោក; ទំនៀមស្រុកទេស។

↳ **លោកបាល** : អ្នករក្សាលោក គឺមហារាជ៤អង្គជាអ្នកគ្រប់គ្រងរក្សាលោក។

↳ **លោកប្បវត្តិ** : លោកប្រវត្តិ, ពង្សាវតារលោក។

↳ **លោកប្រវត្តិ** : លោកប្បវត្តិ, ពង្សាវតារលោក។

↳ **លោកប្រទីប** : ប្រទីប (ពន្លឺ) របស់លោក (ព្រះសព្វញ្ញុពុទ្ធ)។

↳ **លោកប្រសិទ្ធ** : ដែលប្រាកដ, ជាក់ច្បាស់ដល់ពួកមនុស្សទូទៅ, ដែលមានគេដឹងឬដែលមានគេស្គាល់ពេញពាស។

↳ **លោកយាត្រា** : ដំណើរ, ការប្រព្រឹត្តទៅរបស់លោក; កិច្ចការរបស់មនុស្ស; ការរស់នៅរបស់សត្វលោក។

↳ **លោកវឌ្ឍនៈ** : លោកវុឌ្ឍិ, សេចក្ដីចម្រើនរបស់លោក។

↳ **លោកវាទ** : លោកវោហារ, សម្ដីឬវោហាររបស់លោក។

↳ **លោកវិជ្ជា** : លោកវិទ្យា, វិជ្ជាសម្រាប់លោក។

↳ **លោកវិទ** : អ្នកចេះវិជ្ជាសម្រាប់លោក។

↳ **លោកវិទូ** : អ្នកដឹងច្បាស់នូវលោក (ព្រះសម្មាសម្ពុទ្ធ)។

↳ **លោកវិនាស** : សេចក្ដីវិនាសលោក, ការប្រល័យលោក។

↳ **លោកសក្ខី** : លោកសាក្សី, បន្ទាល់របស់លោកគឺ ភ្លើង; ព្រះព្រហ្ម។

↳ **លោកសណ្ឋាន** : ទ្រង់ទ្រាយឬបែបភាពពិភពលោក, ភូគោល។

↳ **លោកសន្តិភាព** : សេចក្ដីស្ងប់របស់លោក។

↳ **លោកសន្តិសុខ** : ដំណើរសុខសាន្តរបស់លោក។

↳ **លោកសន្និវាស** : ពពួកសត្វដែលនៅអាស្រ័យក្នុងលោក, ពួកមនុស្ស; លោកទាំងអស់។

↳ **លោកសព្ទ** : សូរសព្ទរបស់លោក; ភាសាសម្ដីរបស់សត្វលោក។

↳ **លោកស្ថិតិ** : ដំណើរស្ថិតនៅរបស់លោក, ដំណើរដែលលោកតាំងនៅតាមកាលកំណត់; អាយុផែនដី។

↳ **លោកហាស** : លោកហាសៈ, សេចក្ដីរីករាយរបស់ពួកមនុស្ស...។

↳ **លោកាធិបតី** : អធិបតីរបស់លោក (មហាព្រហ្ម); ម្ចាស់របស់លោក, ម្ចាស់ទ្វីប (ស្ដេចចក្រពត្តិ)។

↳ **លោកាធិបតេយ្យ** : ការប្រកាន់យកលោកជាធំ គឺការខ្លាចចិត្តពួកមនុស្សផងគ្នា; ការប្រុងប្រយ័ត្នមិនហ៊ានធ្វើអំពើអាក្រក់ព្រោះខ្លាចគេដឹងនឹងខ្មាស់គេទុកជាមុន។

➢ **លោកាធិប្បាយ** : លោកាភិប្រាយ, សេចក្តីអធិប្បាយអំពីលោកសណ្ឋាន។

➢ **លោកានុវត្តន៍** : លោកានុវត្តិ, ការប្រព្រឹត្តតាមលោក គឺការអនុលោមតាមបែបរបស់មនុស្សផងគ្នា ការយកតម្រាប់គ្នា។

➢ **លោកានុវត្តិ** : លោកានុវត្តន៍, ការប្រព្រឹត្តតាមលោក គឺការអនុលោមតាមបែបរបស់មនុស្សផងគ្នា ការយកតម្រាប់គ្នា។

➢ **លោកាមិស** : លោកាសៈ, នុយរបស់សត្វលោក គឺបញ្ចកាមគុណ (រូប, សំឡេង, ក្លិន, រស, សម្ផស្ស)។

➢ **លោកាសៈ** : លោកាមិស, នុយរបស់សត្វលោក គឺបញ្ចកាមគុណ (រូប, សំឡេង, ក្លិន, រស, សម្ផស្ស)។

➢ **លោកាយតៈ** : លោកាយតសាស្ត្រ, គម្ពីរសម្តែងគតិលោកដែលមានដំណើរសេចក្តីរយីករយាកមិនគួរជឿឬគម្ពីរ ដែលមានសេចក្តីបដិសេធថា ឋានសួគ៌ ឋាននរក មិនមាន។

➢ **លោកាយតិកៈ** : អ្នកដែលស្ទាត់ជំនាញខាងលោកាយតសាស្ត្រ; បើស្ត្រីជា លោកាយតិកា។

➢ **លោកុត្តរ** : លោកុត្តរធម៌, ធម៌ចម្លងសត្វឱ្យចេញផុតចាកលោក គឺមគ្គ៤, ផល៤, និព្វាន១; ហៅថា នវលោកុត្តរធម៌ ក៏បាន។

↳ **លោកុត្តរធម៌** :  លោកុត្តរ,  ធម៌ចម្លងសត្វឱ្យចេញផុតចាកលោកគឺ មគ្គ៤, ផល៤, និព្វាន១; ហៅថា នវលោកុត្តរធម៌ ក៏បាន។

↳ **លោកុត្តរចិត្ត** : ចិត្តដែលឆ្លងផុតចាកលោកគឺចិត្តរបស់អរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ។

↳ **លោកុត្តរសម្បត្តិ** : មគ្គផលនិព្វាន។

↳ **លោកុត្តរាភិសម័យ** : ការបានសម្រេចមគ្គផល។

↳ **លោកុត្តរារិយមគ្គ** : ផ្លូវអរិយបុគ្គលសម្រាប់ឆ្លងចាកលោក។

↳ **លោកេស** :  អ្នកជាចម្បងជាងសត្វលោកគឺ  ព្រះសម្មាសម្ពុទ្ធ (តាមលទ្ធិព្រាហ្មណ៍ថា មហាព្រហ្ម)។

↳ **លោកេស្វរៈ** : អ្នកដែលជាធំក្នុងលោកឬជាងសត្វលោក។ នាមពោធិសត្វ  ដែលពួកពុទ្ធសាសនិកខាងឧត្តរនិកាយឬមហាយានសន្មតដោយផ្សំផ្សំតាមមតិរបស់ខ្លួន, ប្រកាសជំនឿថាជាធំខាងការបីបាច់រក្សាសត្វលោកក្នុងសាសនារបស់ ព្រះសក្យមុនីគោតម, ផ្ទៀបគ្នានឹង មហាព្រហ្ម ឬ វិស្ណុរបស់ពួកព្រាហ្មណ៍ (ហៅ អវលោកេស្វរៈ ក៏បាន)...។

↳ **ភាជនលោក** :  ប្រទេសសម្រាប់សត្វលោកនៅអាស្រ័យ,  កន្លែងកើតស្លាប់របស់ពពួកសត្វ។

↳ **ទេវលោក** : ឋានសួគ៌ ។

↳ **បរលោក** : លោកខាងមុខ។

- **បេតលោក** : ប្រេតលោក, ឋានប្រេត , លំនៅរបស់ពួកប្រេត។
- **ប្រេតលោក** : បេតលោក, ឋានប្រេត , លំនៅរបស់ពួកប្រេត។
- **ព្រហ្មលោក** : ឋានព្រហ្ម។
- **មនុស្សលោក** : ឋានមនុស្ស; មនុស្សប្រុសស្រី។
- **យមលោក** : អបាយលោក, អបាយភូមិ។
- **អបាយលោក** : យមលោក, អបាយភូមិ។
- **សត្តលោក** : សត្វលោក, ពពួកសត្វ។
- **សត្វលោក** : សត្តលោក, ពពួកសត្វ។
- **ឥធលោក** : លោកនេះ, ជាតិនេះ។
- **ឱកាសលោក** : ភាគអាកាស...។

**លោក**២ *ឞ.ស.* ព្រះអង្គ; អ្នក; គាត់។

ពាក្យគោរពសម្រាប់និយាយជាជំនួសឈ្មោះបុគ្គលថ្នាក់ខ្ពស់ជាងខ្លួនឬថ្នាក់ស្មើនឹងខ្លួនដែលត្រូវនិយាយទៅរកឬដែលត្រូវនិយាយដល់ :

- អញ្ជើញលោកពិសា!
- លោកមិនអញ្ជើញមកទេ។

សម្រាប់ប្រើផ្សំពីខាងដើមនាមនាម ដែលគួរប្រកបដោយសេចក្ដីគោរព :

- លោកអ្នកឧកញ៉ា...

❖ លោកអភិបាលខេត្ត

❖ លោកនាយ

❖ លោកឪពុក

❖ លោកគ្រូ

❖ លោកតា

❖ លោកយាយ

❖ លោកមា

❖ លោកក្មួយ...។

🌹 សម្រាប់ហៅបព្វជិតទាំងពួង :

❖ និមន្តលោកឆាន់...។

**លំនៅ** *ន.* កន្លែងដែលនៅ, កន្លែងសម្រាប់នៅ, ទីដែលនៅ, ទីសម្រាប់នៅ :

❖ ព្រៃជាលំនៅរបស់សត្វ

❖ ផ្ទះជាលំនៅរបស់មនុស្ស។

📖 គួរកុំប្រើ **ទីលំនៅ** ព្រោះ លំនៅ ជានាមសព្ទប្រាប់សេចក្ដីថា ទីសម្រាប់នៅស្រេចទៅហើយ បើថែមពាក្យ ទី មកទៀតនាំឱ្យផ្ទួន នាំឱ្យធ្ងន់, បើត្រូវការប្រើពាក្យ ទី ត្រូវថា ទីនៅ ឬ ទីជាលំនៅ ក៏គឺ លំនៅហ្នឹងឯង។

**វិប្បដិសារី** *ន.* អ្នកដែលមានសេចក្ដីក្ដៅក្រហាយចិត្ត, អ្នកដែលមានសេចក្ដីនឹកស្ដាយក្រោយ, អ្នកដែលមានសេចក្ដីនឹកតូចចិត្តព្រោះដឹងខ្លួនជាខុស។

បើស្ត្រីជា ខប្បដិសារិនី។

➷ **មានវិប្បដិសារៈ** (កុំប្រើថា មានខប្បដិសារី ព្រោះពាក្យនេះជាការកនាម នាមដែលជា ឈ្មោះមនុស្ស ឬ សត្វ អ្នកទទួលសម្រេចនូវអំពើដោយខ្លួនឯងស្រេចហើយ)។

**សណ្ដាប់១** *ន.* ទម្លាប់ដែលកើតមានដោយបានស្ដាប់ឮតៗមក, ទំនៀម, បែប, បែបបទ :

- ❖ សណ្ដាប់ស្រុក
- ❖ សណ្ដាប់ប្រទេស
- ❖ សណ្ដាប់មាតាបិតា
- ❖ ធ្វើតាមសណ្ដាប់បុរាណពីព្រេងនាយ។

**សណ្ដាប់២** *កិ.* (រ.ស.) ស្ដាប់ "ស្ដេចស្ដាប់" :

**ទ្រង់ព្រះសណ្ដាប់** : ទ្រង់ស្ដាប់។

**សម្ដេច១** *ន.* លោកអ្នកមានតេជះច្រើន, លោកអ្នកមានបុណ្យមានអំណាចធំ។

**សម្ដេច២** *គុ.* ខ្ពង់ខ្ពស់, ឧដុង្គឧត្ដម, ដែលថ្កើងសក្ដិ ដែលថ្កើងអំណាច, ដែលថ្កើងថ្កាន។

❀ ពាក្យសម្រាប់ប្រើបន្ថែមលើ ព្រះនាម ឬលើឋានន្ដរ ក្សត្រ មន្ត្រីសក្ដិខ្ពស់ :

- ❖ ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី...

❖ សម្ដេចព្រះមហាក្សត្រិយានី

❖ សម្ដេចព្រះឧបយុវរាជ

❖ សម្ដេចព្រះឧភយោរាជ

❖ សម្ដេចព្រះវររាជជននី

❖ សម្ដេចព្រះមហាឧបរាជ

❖ សម្ដេចព្រះសង្ឃរាជ

❖ សម្ដេចព្រះរៀម

❖ សម្ដេចព្រះអនុជ...។

**សម្ដេចចៅពញា** : ឋានន្តរសេនាបតីទី១សម្រាប់ទោ (មានតែពីក្នុងសម័យបុរាណ) ...។

**សម្បុរ** *ន.* ពណ៌ (សម្រាប់ប្រើចំពោះ មនុស្ស និង សត្វនិករ ទាំងពួង) :

❖ ខ្ញុំដើរអំបាញ់មិញនេះប្រទះមនុស្សកំលោះម្នាក់រាងស្ដើង សម្បុរសណ្ដែកបាយដឹកគោកម្រៀវមួយសម្បុរត្នោត។

☞ កុំនិយាយថា :

ô គោ ពណ៌ ត្នោត

ô មនុស្ស ពណ៌ សណ្ដែកបាយ, ...។

**សម្រាន្ត១** *កិ.* ធ្វើឱ្យស្រាន្ត។

**ដេក** (សម្រាប់គ្រហស្ថជាឥស្សរជនឬគ្រហស្ថដែលគួរគោរព) :

❖ លោកកំពុងសម្រាន្ត

❖ អញ្ជើញម៉ែសម្រាន្ត!។

**សម្រាន្ត២** *គុ.* ដែលស្ងប់ឥតទុក្ខភ័យ, ដែលមានសុខស្រួល :

➢ **សុខសម្រាន្ត** : សុខសាន្ត។

**សម្រាប់១** *គុ.* ដែលមានស្រាប់, ដែលបម្រុង, ដែលត្រូវប្រកបតាមការ :

❖ ក្រដាសជារបស់សម្រាប់សរសេរ

❖ ដែកជារបស់សម្រាប់ប្រើការបានច្រើនយ៉ាង។

➢ **មន្ត្រីសម្រាប់ឯក** : មន្ត្រីសម្រាប់ក្សត្រទ្រង់រាជ្យ

➢ **សម្រាប់ទោ** : សម្រាប់ក្សត្រឧភយារាជ,...(ក្នុងសម័យពីដើម)។

**សម្រាប់២** *ន.* ចង្ហាន់ដែលទាយកទាយិការៀបផ្គត់ផ្គង់បម្រុងឬប្រចាំទុកឱ្យមានស្រេចស្រាប់ ដើម្បីប្រគេនបព្វជិតរាល់ថ្ងៃ :

❖ រៀបចង្ហាន់ពីរសម្រាប់

❖ រៀបសម្រាប់ប្រគេនលោក។

❀ ភោជនាហារដែលគ្រហស្ថរៀបផ្គត់ផ្គង់គ្រហស្ថជានិច្ចហៅ **សម្រាប់** ដែរក៏មានតែមិនសូវប្រើ។

❀ វត្ថុដែលបម្រុងឱ្យមានស្រាប់, ប្រដាប់ :

❖ ខោអាវមួយសម្រាប់

❖ ស្បែកជើងពីរសម្រាប់។

**សម្រាយ** *ន.* ពាក្យឬសេចក្ដីដែលប្រែស្រាយពីភាសាដទៃមកជាភាសាសម្រាប់ជាតិ។

📖 ច្រើនហៅចំពោះពាក្យឬសេចក្ដីដែលប្រែពីបាលីឬសំស្រ្កឹតមកជាភាសាខ្មែរ :

- ❖ ពាក្យសម្រាយ
- ❖ សេចក្ដីសម្រាយ
- ❖ សាត្រាសម្រាយ
- ❖ សាត្រានុះមានបាលីមានសម្រាយ។

**សាង១** *កិ.* កឱ្យកើតឡើង, ធ្វើឱ្យកើតឡើង, សង់ឱ្យកើតឡើង (ចំពោះការកុសល) :

- ❖ សាងសាលា
- ❖ សាងចេតិយ
- ❖ សាងព្រះពុទ្ធរូប
- ❖ សាងគម្ពីរព្រះត្រៃបិដក។

**សាងសង់** : សង់សម្អិតសម្អាងឱ្យបានកើតឡើងជាការកុសល។

**សាងសូម** : សាងហើយប្រាថ្នាថាសូមឱ្យបានសម្រេចតាមបំណង។

**សាង២** *ន.* នេសាទុបករណ៍មួយប្រភេទមានផ្លែ៥ឬ៦ បែងជាចង្វែកក្រញាងធ្វើដោយឫស្សីឬដែកមានដងវែង សម្រាប់ចាក់ត្រីតូចៗឱ្យត្បៀតជាប់ក្នុង

ចង្អៃកផ្គែ។

❀ ប្រដាប់ធ្វើដោយឫស្សីមានសណ្ឋានដូចជា សាងសម្រាប់ដោតអំពៅ ដែលកាត់ជាកង់ខ្លីៗ :

❖ អំពៅមួយសាង

❖ ធ្វើសាងដោតអំពៅ។

***ស៊ី** កិ. (ព.សា.)* បរិភោគភោជនាហារ។

❀ និយាយចំពោះអ្នកបរិភោគ, ប្រើតាមថ្នាក់បុគ្គលដូច្នេះ :

| | |
|---|---|
| ❖ សម្រាប់ **ក្សត្រ** | ថា សោយ |
| ❖ សម្រាប់ **បព្វជិត** | ថា ឆាន់ |
| ❖ សម្រាប់ **មន្ត្រីធំ** | ថា ពិសាក្រយា |
| ❖ សម្រាប់ **មន្ត្រីតូចដែលគួរគោរព** | ថា ពិសា |
| ❖ សម្រាប់ **សាធារណជនដែលគួរគោរព** | ថា ពិសា |
| ❖ សម្រាប់ **សាធារណជនធម្មតា** | ថា ហូប |
| ❖ សម្រាប់ **ជនស្មើគ្នា** | ថា ហូប។ |
| ❀ ពាក្យកណ្តាល | ថា បរិភោគ |

➷ សម្រាប់ **សាធារណជនអ្នកតូចផង** និយាយគួរសមថា អាស្រ័យ :

❖ មើលនាំគ្នាអាស្រ័យបាយទៅ!

❀ ពាក្យសាមញ្ញ :

❖ សម្រាប់ **សាធារណជន** ថា ស៊ី (បុរាណថា ឆី)។

🌹 ពាក្យលំអុត :

❖ សម្រាប់ **កូនតូច** ថា ញ៉ាំ។

🌹 ពាក្យសាមញ្ញទូទៅគោះមើលងាយ :

❖ ច្រាស

❖ ច្រាសច្រំ

❖ បុះ

❖ បុះច្រាស

❖ សុល

❖ អំពះ។

🌹និយាយចំពោះខ្លួនឯងជាអ្នកបរិភោគ បើនិយាយតាមថ្នាក់ដូច្នេះ :

❖ ក្នុងទីចំពោះព្រះភក្ត្រក្សត្រថា ទទួលព្រះរាជទាន

❖ ក្នុងទីចំពោះមុខឥស្សរជនក្រៅពីក្សត្រថា ទទួលទាន

❖ ក្នុងទីចំពោះមុខសាធារណជនដែលគួរគោរពថា ទទួលទាន

❖ ក្នុងទីចំពោះមុខសាធារណជនយ៉ាងកណ្ដាលថា បរិភោគ

❖ ក្នុងទីចំពោះគ្នាស្មើថា អាស្រ័យ ឬថា ស៊ី។

✍ ចំណែកខាងបព្វជិតថា ឆាន់ (ដូចជាអ្នកដទៃនិយាយចំពោះមករក

ខ្លួនដែរ) :

❖ អាត្មាឆាន់រួចហើយ។

ឥស្សរជននិយាយពីខ្លួនជាអ្នកបរិភោគទៅរកសាធារណជនតូចជាងថា អាស្រ័យ, ឬនិយាយដោយគួរសមថា ឧទ្ធលឆាន...។

ពាក្យ ស៊ី នេះប្រើសំដៅ សេចក្ដីចំពោះ និង សេចក្ដីប្រៀប បានជាអនេក, ដូចជា :

**ស៊ីកម្រៃ** : យកកម្រៃឬគេឱ្យបានកម្រៃខ្លះ។

**ស៊ីការប្រាក់** : យកការប្រាក់, បានការប្រាក់ជាប្រយោជន៍។

**ស៊ីកម្លាំង** : ពឹងកម្លាំងគេឬរស់ដោយសារគេចិញ្ចឹម។

*ឧ.* មាតាបិតាស៊ីកម្លាំងបុត្រ។

**ស៊ីក្នុង** : រូងសាច់ចូលទៅក្នុង, ស៊ីរូង ។

*ឧ.* ដំបៅស៊ីក្នុង។

**ស៊ីក្រចក** : ចាប់ត្រង់សាច់ក្បែរក្រចកមើលមិនជា។

*ឧ.* ស្រែងស៊ីក្រចក។

**ស៊ីក្រោមភ្នែក** : បំបាត់នៅមុខឬលួចប្រពន្ធគេបានដោយងាយ។

**ស៊ីខារ** : ជក់ខ្យល់ចំហៀងឬទទឹង។

*ឧ.* ក្ដោងស៊ីខារ។

**ស៊ីគំនិត** : លួចគំនិតគ្នា, ដេញគំនិតគ្នា, ស៊ីប្រាជ្ញា។

**ស៊ីគ្នា** : ត្រូវគ្នា, ដូចគ្នា, សមគ្នា; លើសគ្នា។

**គំនិតស៊ីគ្នា** : គំនិតត្រូវគ្នា។

**ស៊ីចាយ** : ចាយវាយស៊ីផឹកតាមតែប្រទះ។

**ស៊ីចុក** : ស៊ីស្លាចុកថ្នាំ; ចិញ្ចឹមជីវិតតាមប្រក្រតី។

**ស៊ីចុកហុកចំពា** : អត់ឃ្លានមានស៊ីជាមួយគ្នា។

**ស៊ីចំណោញ** : យកចំណេញ។

**ស៊ីជី** : ចាប់យកជាតិជី, ស្រូបយកជាតិជី។

*ឧ.* ដីស៊ីជី។

**ស៊ីជើង** : កាត់សាច់ចង្កេះក្រោមជើង។

*ឧ.* ទឹកស៊ីជើង។

**ស៊ីជំនោរ** : ឡើងបញ្ហោរ, ស៊ីបញ្ហោរ។

*ឧ.* មនុស្សស៊ីជំនោរ។

**ស៊ីបញ្ហោរ** : ឡើងបញ្ហោរ, ស៊ីជំនោរ។

*ឧ.* មនុស្សស៊ីជំនោរ។

**ស៊ីជម្រៅ** : ដែលមានបាតជ្រៅ, ស៊ីទឹកជ្រៅ (ចំពោះតែនាវា)។

*ឧ.* ទូកស៊ីជម្រៅ។

**ស៊ីទឹកជ្រៅ** : ដែលមានបាតជ្រៅ, ស៊ីជម្រៅ (ចំពោះតែនាវា)។

*ឧ.* ទូកស៊ីជម្រៅ។

**ស៊ីឈ្នួល** : ធ្វើការយកឈ្នួល, ទទួលជួលឱ្យគេ។

**ស៊ីតូច** : ចាយវាយតូច, ស៊ីម្ហូបតិចមុខ។

**ស៊ីថោក** : យកតម្លៃថោក, យកថ្លៃតិច។

**ស៊ីថ្លៃ** : យកថ្លៃច្រើន។

**ស៊ីទម្លាក់** : និយាយពីទូក-ងមាឱរឹង បានតែអុំទម្លាក់ច្រវាឱ្យយាងយារម្ដងៗទើបលឿន, ស៊ីយាងយារ។

*ឧ.* ទូកនេះស៊ីទម្លាក់អុំសាប់មិនលឿនទេ។

**ស៊ីធំ** : ស៊ីម្ហូបច្រើនមុខឬចាយវាយធំ។

**ស៊ីនុយ** : ត្របាក់នុយ, លេបនុយ។

**ស៊ីនៅមុខ** : បំបាត់យកនៅមុខឬលួចនៅមុខ។

**ស៊ីប្រាក់** : បំបាត់ប្រាក់ (មានបំបាត់ប្រាក់រាជការជាដើម) ឬយកប្រាក់សំណូក, ស៊ីប្រាក់កាស ។

**ស៊ីប្រាក់កាស** : បំបាត់ប្រាក់ (មានបំបាត់ប្រាក់រាជការជាដើម) ឬយកប្រាក់សំណូក, ស៊ីប្រាក់។

**ស៊ីប្រាក់ខែ** : បានប្រាក់ដែលត្រូវបើកតាមកំណត់ពេលរៀងរាល់ខែ (មាសិក)។

**ស៊ីប្រាក់ថ្ងៃ** : បានប្រាក់ដែលត្រូវបើកតាមកំណត់ត្រឹមតែថ្ងៃដែលធ្វើការ (ទិនិក)។

**ស៊ីរ៉ុំត្រែត** : បានប្រាក់ដែលខ្លួនអ្នករាជការចាស់ត្រូវបានរៀងរាល់ខែ, ស៊ីប្រាក់រ៉ុំត្រែត, ស៊ីប្រាក់កម្រៃ (ដោយមិនបាច់ធ្វើរាជការ គឺចូលនិវត្តន៍)។

**ស៊ីប្រាក់កម្រៃ** : បានប្រាក់ដែលខ្លួនអ្នករាជការចាស់ត្រូវបានរៀងរាល់ខែ, ស៊ីប្រាក់រ៉ុំត្រែត, ស៊ីរ៉ុំត្រែត (ដោយមិនបាច់ធ្វើរាជការ គឺចូលនិវត្តន៍)។

**ស៊ីប្រេង** : បង្ហួស់ប្រេង, ចុះប្រេង។

*ឧ.* រថយន្តអ្នកស៊ីប្រេងតិចជាងរបស់ខ្ញុំ។

**ស៊ីផឹក** : ស៊ីផងផឹកស្រាផង។

**ស៊ីផេះ!** : គ្មានអ្វីស៊ី, ស៊ីតែផេះ!។

**ស៊ីតែផេះ!** : គ្មានអ្វីស៊ី, ស៊ីផេះ!។

**ស៊ីផ្ដាច់ស្រុក** : យកប្រយោជន៍បានពីស្រុកមួយទាំងមូល។

*ព.ប្រ.* លេងឈ្នះកាយយកគ្រាប់អស់ពីរន្ធមិនឱ្យអ្នកម្ខាងដើរបាន (ក្នុងល្បែងបាយខុំ)។

**ស៊ីផ្លែខ្មោត** : ត្រូវគេបញ្ឆោតឬចាញ់បោកគេ។

**ស៊ីផ្អែម** : ស៊ីចំណីផ្អែម។

*ព.ប្រ.* រកបានដោយងាយៗ, ចំណេញងាយៗ, ងាយបានប្រាក់។

**ស៊ីពីមុខ** : យកបានពីមុខឬបំបាត់យកពីមុខ។

**ស៊ីព្រោះលោះកម្លាំង** : មិនធ្វើការនឿយហត់ព្រមទាំងបានសុខស្រួលដោយសារកូនឬកូនសិស្សចិញ្ចឹមរក្សា។

**ស៊ីមិនមុត** : ធ្វើការមិនកើតឬយកប្រយោជន៍មិនបាន។

**ស៊ីមួយចំហៀងស្រុក** : បានប្រយោជន៍ពីក្នុងស្រុកពាក់កណ្ដាល។

*ឧ.ប្រ.* លេងឈ្នះកាយយកគ្រាប់ពីប៉ែកខាងគេអស់ទាំង៥វន្ទ (ក្នុងល្បែងបាយខុំ)។

**ស៊ីមេកូន** : យកទាំងមេទាំងកូនឬយកទាំងម្ដាយទាំងកូន។

*ឧ.ប្រ.* ស៊ីម្ដងពីរវន្ទ (ល្បែងបាយខុំ)។

**ស៊ីរាក់** : ដែលមានបាតរាក់ (ចំពោះតែនាវា), ស៊ីទឹករាក់។

*ឧ.* ទូកស៊ីរាក់។

**ស៊ីទឹករាក់** : ដែលមានបាតរាក់ (ចំពោះតែនាវា), ស៊ីរាក់ ។

*ឧ.* ទូកស៊ីរាក់។

**ស៊ីរះសងខាង** : ចេះរេបែរលៃលកយកប្រយោជន៍ឱ្យបានពីមនុស្សទាំងពីរខាង។

*ឧ.ឧ.ម្.* នាងតីស្មាគាង ស៊ីរះសងខាងមិនឱ្យឃ្នើសចិត្ត និយាយពីអ្នកដែលចេះផ្គាប់ចិត្តមនុស្សទាំងពីរខាងលើ ដែលទាស់អធ្យាស្រ័យគ្នាមិនឱ្យអាក់អន់ចិត្តមកលើខ្លួនផង ឱ្យកើតប្រយោជន៍មកលើខ្លួនផង ដូចជាស្រីម្នាក់ឈ្មោះ តី ដែលមានប្ដីពីរចេះផ្គាប់ចិត្តប្ដីទាំងពីរមិនឱ្យអាក់អន់។

**ស៊ីវេលា** : អស់វេលា, ខាតវេលា។

*ឧ.* ការនុះស៊ីវេលាច្រើនណាស់។

**ស៊ីសាច់** : បរិភោគសាច់។

*ឧ.ប្រ.* ខឹងខ្លាំង, ខឹងខ្លាំងស្ទើរហ៊ានស៊ីសាច់។

*ឧ.* ខឹងស៊ីសាច់។

**ស៊ីសាប់** : និយាយពីទូក-ឯមាឧទន់បានតែអុំសាប់ឱ្យញាប់ច្រវា ទើបលឿន។

*ឧ.* ទូកនេះស៊ីសាប់ អុំយាងយាវមិនលឿនទេ។

**ស៊ីសោហ៊ុយ** : ចុះសោហ៊ុយ, ត្រូវចាយប្រាក់តាមការប្រកប។

*ឧ.* ការនុះមិនស៊ីសោហ៊ុយច្រើនប៉ុន្មានទេ។

**ស៊ីសំណូក** : ទទួលយកប្រាក់ឬរបស់ដែលគេសូក។

**ស៊ីសំណែន** : ស៊ីភោជនដែលគេសែន។

*ឧ.ប្រ.* ស៊ីសំណូក។

**ស៊ីឡុប** : កិបបំបាត់យក។

**ស៊ីអាចម៍ផឹកទឹក** *(ព.សា.)* អកអាចម៍អាភៀនហើយផឹកទឹក រំលេមលេបជាមួយនឹងទឹកទៅ (លេបអាចម៍អាភៀន)។

**ស៊ី២** *ន.* ពណ៌, សម្បុរ :

- **ស៊ីឆ្នួន** (*ស.* សិន្ធល) សម្បុរ-សលាយលឿងខ្ចីបន្តិចៗ
- សម្បុរ-សលឿងខ្ចីប៉ផូរ។

**សុគត១** *កិ.* ទៅហើយដោយស្រួលឬដោយប្រពៃ។

❀ *ន្ទ.* ដែលទៅហើយដោយស្រួល។

❀ ខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា "ទទួលមរណភាពទៅកើតឯឋានល្អហើយ", និយាយចំពោះតែឥស្សរជនជាតិក្សត្រក្រៅពីព្រះរាជា :

❖ ...ទ្រង់សុគតពីរឆ្នាំហើយ។

**សុគត២** *ន.* អ្នកទៅដោយល្អ; អ្នកបានសម្រេចសុន្ទរធម៌ គឺ ព្រះនិព្វាន; ព្រះនាម **ព្រះសព្វញ្ញុពុទ្ធ** :

❖ ព្រះសុគត។

❀ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ *អ.ថ.* សុគៈតៈ, ដូចជា :

- **សុគតវាចា** : វាចានៃព្រះសុគត (ពុទ្ធភាសិតឬពុទ្ធសាសនា)។
- **សុគតសាវ័ក** : សាវ័ករបស់ព្រះសុគត។
- **សុគតោវាទ** : ឱវាទនៃព្រះសុគត។

**សូម** *កិ.* បញ្ចេញវាចាឬសម្ដែងអាការៈឱ្យគេឱ្យអ្វីៗដែលខ្លួនត្រូវការ :

❖ សូមទាន

❖ សូមប្រាក់

❖ សូមពរ *(ព.សា. សុំ)*។

📖 ពាក្យ សូម សម្រាប់ប្រើនាំមុខឬជាជំនួយកិរិយាសព្ទមានអាការៈជាកិរិយានុគ្រោះឬប្រើជាជំនួយនាមសព្ទក៏បាន ដោយសេចក្ដីអង្វរឬដោយ

សេចក្តីគោរព, ដោយសេចក្តីគួរសម (តាមថ្នាក់បុគ្គល) :

- សូមព្រះតេជះតម្កល់លើត្បូង
- សូមព្រះរាជទាន...
- សូមទ្រង់...
- សូមទ្រង់ជ្រាប
- សូមទ្រង់ព្រះមេត្តាប្រោស...
- សូមទ្រង់មេត្តាប្រោស...
- សូមទាន...
- សូមទានជ្រាប
- សូមជ្រាប
- សូមព្រះបាទម្ចាស់...
- សូមព្រះតេជព្រះគុណ...
- សូមលោក...
- សូមនាយ...
- សូមអ្នក...
- សូមឱកាស
- សូមកុំ...
- សូមឱ្យ...។

**សូមក្រាបបង្គំទូល** *កិ.* និយាយពីពាក្យសម្រាប់ក្រាបទូលព្រះមហាក្សត្រ ជា អម្ចាស់ជីវិត ដោយគារវភាពដ៏ខ្ពង់ខ្ពស់ក្រៃលែង គឺអ្នកសរសេរចុតហ្មាយ នោះសូមក្រាបបង្គំព្រមទាំងសូមយកសិរៈរបស់ខ្លួន ទូលព្រះបាទាព្រះអង្គ ផង ប៉ុន្តែសូមទូលពីក្រោមល្អងធូលីដែលជាប់នៅត្រង់បាតព្រះបាទាដោយ ផ្ដើមសេចក្ដីត្រង់បន្ទាត់លើបំផុតថា *សូមព្រះតេជះគម្ពល់លើត្បូង*; ហើយ សរសេរត្រង់បន្ទាត់ក្រោមបន្ទាត់នោះ ដោយលូកចូលបន្តិចថា *សូមព្រះរាជ ទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង-សូមទ្រង់ជ្រាប*។ រួចសរសេរលូកបន្ទាត់ចូលរាយសេចក្ដីតាមដំណើរការណ៍ ទៅដរាបដល់ចប់។

☞ ***នេះជាបែបបូរាណតាំងពីបុរាណកាលមក***...។

**សេចក្ដី** *ន.* ដំណើរ; ហេតុ; ការណ៍; គតិ; លំអាន; ផ្ទៃរឿង; គ្វាម; ដំណើរពាក្យ :

- ❖ តែងសេចក្ដី
- ❖ មិនយល់សេចក្ដី
- ❖ រាយសេចក្ដីមិនបែក
- ❖ អស់សេចក្ដីត្រឹមប៉ុណ្ណោះ
- ❖ ធម៌នេះមានសេចក្ដីជ្រាលជ្រៅ។

🌹 ពាក្យជាកិរិយាសព្ទឬគុណសព្ទដែលមិនបែកចេញទៅជាសាធនៈ ឱ្យជា នាមនាម :

✍ ដូចជាកិរិយាសព្ទថា :

❖ ក្រើន

❖ ចម្រើន

❖ បន្ទោស

❖ យល់

❖ សរសើរ

❖ ស្ដាប់ ជាដើម។

✍ ដូចជាគុណសព្ទ ថា :

❖ ល្អ

❖ អាក្រក់

❖ ជំនាញ

❖ ឈ្លាស ជាដើម។

🌹 កាលណាត្រូវការឱ្យទៅជា នាមនាម ត្រូវប្រើពាក្យថា :

❖ សេចក្ដី នេះរៀងពីខាងដើម ជាជំនួយទើបទៅជា នាមនាម បាន (ចំពោះតែអរូបនាម) :

➥ **សេចក្ដីក្រើន** (ដែលគួរប្រើជា កម្រើន ៗ.), សេចក្ដីចម្រើន, សេចក្ដី

បន្ទោស, សេចក្ដីយល់, សេចក្ដីសរសើរ, សេចក្ដីស្លាប់; សេចក្ដីល្អ; សេចក្ដីអាក្រក់; សេចក្ដីជំនាញ; សេចក្ដីឈ្លាស។

☞ ឯពាក្យដែលបែកចេញពី **កិរិយាសព្ទ** ឬពី **គុណនាម** ដោយមាន **វគ្គហៈ** ចេញទៅជា **សាធនៈ** ឱ្យកើតបានទៅជា **នាមនាម** (***រូបនាម ឬ អរូបនាម***) ស្រេចហើយនោះមិនត្រូវប្រើពាក្យថា **សេចក្ដី** នេះផ្សំផងទេ, ដូចជា :

- **កើត** > កំណើត
- **ចង** > ចំណង
- **ចង់** > ចំណង់
- **ចុច** > ចំណុច
- **ចេះ** > ចំណេះ
- **ត្រិះ** > តម្រិះ
- **ប៉ង** > បំណង
- **ព្រាម** > បម្រាម
- **សូក** > សំណូក
- **ខុស** > កំហុស
- **តូច** > តំណូច
- **ធំ** > ធំហំ
- **អរ** > អំណរ ជាដើម។

☞ ពាក្យដែលត្រូវប្រើ សេចក្ដី ជាជំនួយនោះចួនណាគួរឱ្យប្រើពាក្យ ការ, ដំណើរ ជាដើម ជាជំនួយវិញក៏មាន :

❖ ការក្រ

❖ ការប្រាប់

❖ ការពន្យល់

❖ ការអាក្រក់

❖ ដំណើរទៅមក...។

**សោក១** *ន.* សេចក្ដីឈឺផ្សាចិត្ត; សេចក្ដីសង្រេង; សេចក្ដីស្ដាយស្រណោះ ឬស្ដាយអាល័យ :

❖ មានសោក

❖ រំងាប់សោក។

☞ ខ្មែរប្រើជា *កិ.* ក៏មាន "ស្ដាយស្រណោះ, ស្ដាយអាល័យ" :

❖ សោកកូនដែលស្លាប់

❖ សោកទ្រព្យដែលលាញ (*ព.ការ.* ប្រើជា សោភា ក៏មាន)។

**យំសោក** : យំស្ដាយស្រណោះ។

**សោយសោក** : ទទួលរងសេចក្ដីស្ដាយស្រណោះ។

**សោកសៅ** : សោកទាល់តែសៅសម្បុរ, សោកសង្រេង, សោក ជ្រប់ខ្លាំង, សៅសោក, ...។

🦟 **សៅសោក** : សោកទាល់តែសៅសម្បុរ, សោកសង្រេង, សោកជ្រប់ខ្លាំង, សោកសៅ, ...។

**សោក២** *ន.* ឈ្មោះឈើមួយប្រភេទ ស្លឹកខ្ចីសម្បុរសភាវៈ ផ្កាសម្បុរក្រហមប្រឿង ក្លិនស្រដៀងនឹងផ្កាអម្ពិល ស្លឹកខ្ចីប្រើជាអន្លក់បាន ផ្កាប្រើស្ល ម្ជូរឬជ្រក់បាន :

❖ ដើមសោកជាឈើមានលម្អគួរដាំក្នុងវត្តអារាម (*ឝ.* អសោក; គួរហៅតាម នាម នេះវិញ)។

**សោមនស្ស** *ន.* សេចក្ដីសប្បាយចិត្ត, សេចក្ដីរីករាយសប្បាយ; អំណរ។

📖 **មានសោមនស្ស** មិនបាច់ប្រើ សេចក្ដី ផ្សំជា សេចក្ដីសោមនស្ស ទេ។ *ព.ផ្ទ.* ទោមនស្ស។

🦟 **សោមនស្សវេទនា** : ដំណើរទទួលអារម្មណ៍ជា សោមនស្ស។ *ព.ផ្ទ.* ទោមនស្សវេទនា។

**សុំ** *កិ.* *(ព.សា.)* សូម :

❖ សុំទាន

❖ សុំគេស៊ី។

📖 ពាក្យ សុំ សម្រាប់អ្នកធំនិយាយទៅរកអ្នកតូចដោយសេចក្ដីអង្វរ ឬដោយសេចក្ដីគួរសម :

❖ សុំឱ្យឯងអាណិតអញ

❖ រាជការសុំឱ្យអស់បណ្ដារាស្ត្រយកចិត្តទុកដាក់ខំប្រឹងធ្វើការនេះឱ្យបានសម្រេចឆាប់។

**សំណាង** *ន.* អំពើដែលកសាង, ភ័ព្វព្រេង, ព្រេងពីនាយ :

❖ សំណាងល្អ

❖ សំណាងតិច

❖ សំណាងអាក្រក់។

**មានសំណាង** : មានភ័ព្វព្រេងល្អ, មានបុណ្យភ័ព្វពីព្រេងនាយមក។

**សំពត់** *ន.* របស់កើតអំពីការត្បាញដោយអំបោះ, សូត្រ, សរសៃវល្លិ, សំបកឈើ, រោមចៀម ជាដើមសម្រាប់ស្លៀក, សម្រាប់ដណ្ដប់ជាដើម :

❖ សំពត់អំបោះ

❖ សំពត់សូត្រ

❖ សំពត់សំបកឈើ...។

**កំណាត់** ឬ **កំណាត់សំពត់** : សំពត់ចាស់ឬសំពត់ដែលប្រឡាក់, សៅហ្មងដែលគេលែងប្រើស្លៀកដណ្ដប់ ហើយសម្រាប់គ្រាន់តែជូតអ្វីៗប៉ុណ្ណោះដូចជា :

❖ កំណាត់ជូតក្ដារសរសេរ

❖ កំណាត់សំពត់ជូតជើង...។

🕮 បើ សំពត់ថ្មី ឬ សំពត់ស្អាត ដែលគេបត់ជា ផាប់ ឬបត់ជា ភី ក្ដី ទោះបីគេកាត់ប្រវែងមួយម៉ែត្រពីរម៉ែត្រក្ដី មួយអាវពីរអាវក្ដី ពុំគួរហៅ កំណាត់ ឬ កំណាត់សំពត់ ឡើយ ត្រូវហៅត្រឹមតែ សំពត់ៗ ប៉ុណ្ណោះ ដូចជាថា :

- ❖ សំពត់មួយម៉ែត្រ
- ❖ សំពត់មួយត្បូង
- ❖ សំពត់មួយអាវ...។

☛ ខ្មែរក្នុងសម័យបុរាណហាមមិនឱ្យប្រើសម្ដី :

✍ **ធំ** កុំថាជា តូច

✍ **ច្រើន** កុំថាជា តិច

✍ **ខ្ពស់** កុំថាជា ទាប

✍ **សំពត់** កុំថាជា កំណាត់

✍ **ប្រាក់** កុំថាជា លុយ

✍ **ថ្លៃ** កុំថាជា ថោក ជាដើម។

➥ ព្រោះនាំឱ្យ ធ័លគ្រ, ព្រោះនាំឱ្យ ថយថោក, ព្រោះនាំឱ្យ អាប់ឱន, ព្រោះនាំឱ្យ ឆន់ទាប, ព្រោះនាំឱ្យជាសម្ដី អត័ព្វ (ក្រែងនឹងដូចមាត់ថា)។

**ស្ដាប់** *គិ.* ប្រុងត្រចៀកទទួលចាំឮ :

- ❖ ស្ដាប់ធម៌
- ❖ ស្ដាប់ភ្លេង។

❀ ទទួលឱវាទត្រងត្រាប់, យកពាក្យ, យកសម្ដី, ទទួលធ្វើតាម :

❖ ស្ដីមិនស្ដាប់

❖ ស្ដាប់ពាក្យប្រដៅ។

**ជឿស្ដាប់** : ស្ដាប់ហើយជឿតាម, ស្ដាប់ហើយទទួលប្រតិបត្តិតាម។

**ស្ដែងស្ដាប់** : ជាក់ច្បាស់, ជាក់ស្បាន់, ដែលគួរស្ដែង។

*ឧ.* ធ្វើឱ្យឃើញស្ដែង។

**ស្ដាយ** *(ខើង ដ)* *កិ.* នឹកអាល័យ, នឹកឃើញហើយមិនអស់ចិត្ត មិនអស់អាល័យ, ជំពាក់ដោយអាល័យ :

❖ ស្ដាយទ្រព្យ

❖ ខ្ញុំស្ដាយណាស់ដោយមិនបានទៅ...។

**ស្ដាយក្រោយ** : នឹកឃើញហើយស្ដាយជាខាងក្រោយ, កើតក្ដៅក្រហាយចិត្តជាខាងក្រោយ។

**ស្ដាយតំនិត** : នឹកតូចចិត្តព្រោះធ្លោយហួសទៅហើយ។

**ស្ដាយស្រណោះ** : នឹកអាឡោះអាល័យ ស្រណោះដល់...។

📖 បើគ្រាន់តែ **ស្ដាយ** ឥតមានការយំសោកផងទេ កុំប្រើពាក្យថាសោកស្ដាយ ត្រូវប្រើត្រឹមតែ ស្ដាយ, នឹកស្ដាយ, គួរស្ដាយ, គួរឱ្យស្ដាយប៉ុណ្ណោះបានហើយ :

❖ ខ្ញុំនឹកស្ដាយណាស់។

**ស្ដេច១** *ន.* ក្សត្រ, អ្នកដែលកើតក្នុងវង្សក្សត្រ :

❖ ជាតិស្ដេច

❖ ទីដែលស្ដេចគង់។

**ស្ដេច២** *កិ. (រ.ស.)* យាង, ទៅ, មក, ដើរ, ទ្រង់ចេញព្រះរាជដំណើរ :

❖ ព្រះករុណាទ្រង់ស្ដេចទៅខេត្តក្រៅ។

**ស្ដេចភ្នំ** : ភ្នំដែលធំខ្ពស់ចម្បងជាងភ្នំនានា (ភ្នំ ព្រះសុមេរុ៍, ភ្នំ ហិមពាន្ត ឬភ្នំ ហិមាល័យ)។

**ស្ដេចម្រឹគ** : ម្រឹគដែលមានអានុភាពជាងម្រឹគនានា (សីហៈ)។

**ស្ដេចសត្វ** : សត្វដែលមានអំណាចលើពួករបស់ខ្លួន ដូចជា :

❖ ស្ដេចខ្លា

❖ ស្ដេចពស់

❖ ស្ដេចហង្ស។

**ស្ដេចស្ដែង** : ស្ដេចជាក់ស្ដែង, អ្នកដែលប្រាកដជាស្ដេច, ស្ដេចសុទ្ធ។

**ស្ដែងស្ដេច** : ស្ដេចជាក់ស្ដែង, អ្នកដែលប្រាកដជាស្ដេច, ស្ដេចសុទ្ធ។

**ឡើងជាស្ដេច** : ឡើងពីរាស្ត្រទៅជាស្ដេច...។

**ស្ទាវ** *គុ.* ជំទង់ (ចំពោះតែសត្វតិរច្ឆានឈ្មោលពួកខ្លះ) :

❖ គោស្ទាវ

❖ មាន់ស្ទាវ។

**ស្នើ១** *កិ.* សួរឱ្យដឹងសិន, ពិគ្រោះឬប្រឹក្សាមុនសិន (ចំពោះតែជាមួយនឹង **ឥស្សរជន** គឺក្រាបបង្គំទូល, ក្រាបទូល, ទូល, ពិត, ជម្រាប ឱ្យដឹងការមុនសិន) :

❖ ស្នើការ

❖ ទូលស្នើ។

**ស្នើ២** *គុ.* ស្រទាប់, សង្កាត់ដែលសើរើឡើងបានដោយងាយ :

❖ ស្នើក្រដាស

❖ រើយកតាមស្នើ។

*ន.* ចំនួនពីរគួបគ្នា (ចំពោះតែ សន្លឹក ដូចយ៉ាង ម្លូ ជាដើម) :

**ម្លូប្រាំស្នើ** : ម្លូដប់សន្លឹក។

**ស្លាប់** *កិ.* អស់ខ្យល់ដង្ហើម, អស់ជីវិត។ (*ទេ.*) :

❖ បរិនិព្វាន

❖ សោយទិព្វជង្គត

❖ សោយទិវង្គត

❖ សោយពិរាល័យ

❖ សុគត

❖ សុរគត

❖ ក្ស័យ

❖ ក្សិណក្ស័យ

- ទទួលអសញ្ញកម្ម
- ទទួលអសញ្ញភាព
- ទទួលមរណភាព
- ទទួលអនិច្ចធម្ម
- ទទួលអនិច្ចកម្ម
- ធ្វើកាលកិរិយា
- រលត់
- រលត់ខន្ធ
- រំលាងខន្ធ
- ផ្លាយខន្ធ
- ផ្លាយសង្ខារ
- បែកផ្លាយសង្ខារ
- បាត់បង់
- ដើរ
- ផុត
- ផុតរលត់
- ដាច់ខ្យល់
- អស់ដង្ហើម

❖ ងាប់

❖ តាយសាក

❖ តាយហោង

❖ ស្ទឹង

❖ តាយស្ទឹង

❖ តេន

🕮 ប្រើតាមថ្នាក់ :

✍ **ថ្នាក់ខ្ពស់**

✍ **ថ្នាក់កណ្ដាល**

✍ **ថ្នាក់ទាប**

✍ **ថ្នាក់សាមញ្ញ**។

**ទឹកស្លាប់** *ន.* ទឹកដែលគេលត់ដែកឬលត់លោហជាតិណាមួយ។

**នាឡិកាងាប់** *ន.* នាឡិកាឈប់ដើរ, នាឡិកាមិនដើរ។

**ហែ** *កិ.* ដើរជាក្បួនចោមរោមមនុស្សឬអ្វីៗដែលត្រូវសម្ដែងសេចក្ដីគោរពទៅរក :

❖ ហែសព

❖ ហែនាគ

❖ ហែកឋិន

❖ ហែព្រះពុទ្ធរូប។

*រ.ស.* ជូនឬតាមជូនជាយសបរិវារ, ទៅឬមកកំដរជាគ្នា :

❖ ហែព្រះអង្គម្ចាស់

❖ ហែព្រះករុណាឬហ្លួង។

*កិ.* ដើរបណ្ដោយគ្នាជាជួរ :

❖ ដើរហែៗតាមគ្នា (ដើរដង្ហែគ្នា)។

*ន.* ការដើរចោមរោមជារបៀប :

❖ ក្បួនហែ

❖ ទៅមើលហែ។

**ហ្វូង** *ន.* ពួក, ការប្រជុំ (ចំពោះតែសត្វតិរច្ឆាន) :

❖ ហ្វូងគោ

❖ ហ្វូងបក្សី។

**ឡូយ** *គុ.* ឬ *កិ.វិ.* ពាក្យសាមញ្ញប្រើកាត់ខ្លីមកពីពាក្យ ឡូយថូយ សំដៅសេចក្ដីថា "ផ្កាស, ផ្ដេសផ្ដាស" :

❖ គំនិតឡូយ

❖ កុំឡូយពេក

❖ មនុស្សឡូយ។

**ឡូយថូយ** *គុ.* ឬ *កិ.វិ.* (*យ.*) ដែលមិនយកចិត្តទុកដាក់, សោះអង្គើយ; ខ្ជីខ្ជា; ដែលតាមតែបាន, តាមតែរួចពីដៃ; ដែលឥតប្រយោជន៍; ផ្តេសផ្តាស :

❖ គំនិតឡូយថូយ

❖ ធ្វើការឡូយថូយ។

**ឡើយ** *និ.* ជាដាច់ខាត។

❀ ពាក្យសម្រាប់ប្រើរៀងខាងចុងពាក្យបដិសេធ កុំ, គ្មាន, ពុំ, មិន, អខ្ចី, ឥត, ឥតអខ្ចីមាន, ...ដូចជា :

❖ កុំឡើយ

❖ កុំឱ្យឡើយ

❖ គ្មានអ្វីសោះឡើយ

❖ ពុំបានឡើយ

❖ មិនដែលឃើញឡើយ។

**អង្គខ្ញុំឡើយ** *(ព.បុ.)* : ឥតមានអ្នកណាម្នាក់ទៅឡើយ; ឥតអង្គឺមានឡើយ។

❀ *ព.ភា.* ឡើយណា, ទេណា, សោះណា។

**ឡើយនៃ** : ទេនៃ

**ឡើយហោង** : សោះហោង។

ពាក្យកាព្យ

វីពាក្យកាព្យថា ឡើយនៃ, ឡើយណា និងពាក្យឡើយហោង
កវីប្រើផ្សំ កុំឱ្យចួនឆ្គង បើឱ្យហ្មត់ហ្មង
គួរកុំសូវប្រើ។

**អញ** *ទុ.ស.* ខ្ញុំ (ជាអញ្ញត្រសព្ទ)។

ពាក្យសម្រាប់ហៅ ខ្លួនឯង ជាសម្ដីកូនក្មេងនិយាយទៅរកកូនក្មេងផងគ្នា។

ពាក្យសម្រាប់ហៅ ខ្លួនឯង ជាសម្ដីមនុស្សចាស់និយាយទៅរកកូនក្មេង។

ពាក្យសម្រាប់ហៅ ខ្លួនឯង ជាសម្ដីនិយាយទៅរកមនុស្សស្មើភាពដែលស្និទ្ធស្នាល។

ពាក្យសម្រាប់ហៅ ខ្លួនឯង ជាសម្ដីអ្នកធំនិយាយទៅរកអ្នកតូចដោយស្និទ្ធស្នាល :

❖ ឯងទៅចុះ អញមិនទាន់ទៅទេ!។

📖 ខ្មែរបុរាណព្រេងនាយប្រើជា ពាក្យខ្ពស់, មានពាក្យក្នុងសិលាចារឹកថា ទ្រង់កម្រតាងអញ គឺព្រះតេជព្រះគុណរបស់ខ្ញុំឬលោកអ្នកធំរបស់ខ្ញុំ។

| **ពាក្យបុរាណ** | **ពាក្យបច្ចុប្បន្ន** |
|---|---|
| **អញខ្ញុំ** | : ខ្ញុំ |

- **អញខ្ញុំព្រះអង្គ** : ខ្ញុំព្រះអង្គ
- **អញខ្ញុំម្ចាស់** : ខ្ញុំម្ចាស់
- **អញឯង** : ខ្ញុំឯង។

**អធិករអធម** *គុ.* (*បា.សំ.* អធិក "ក្រៃលែង, លើសលែង, លើសលប់, រុងរឿង, ហ៊ឹកហ៊ាក់" + អធម "ថយថោក, ថោកទាប, មិនរុងរឿង, រម៉េះរម៉ោះ, របុិចរប៉ី, រាយរង, បន្ទាប់បន្សំ; ...")។

ខ្មែរប្រើពាក្យ អធិករអធម នេះចំពោះតែពិធីបុណ្យឬពិធីអ្វីមួយដែលរុងរឿងផងរម៉េះរម៉ោះឬរបុិចរប៉ីរាយរងខ្លះផង :

❖ ធ្វើបុណ្យសីមាអធិកអធម៧យប់គម្រប់៧ថ្ងៃ គឺធ្វើបុណ្យសីមានោះមានរបៀបរៀបចំរុងរឿងហ៊ឹកហ៊ាក់ផង មានល្បែងរបាំរម៉េះរម៉ោះនិងការលក់ដូរចេកអំពៅនំចំណីជាដើម របុិចរប៉ី រាយរង ពេញពាសទៅទីជិតៗនោះផង; បើមិនមានលក្ខណៈដូច្នោះទេ ពុំគួរហៅអធិកអធមឡើយ។

*ពាក្យកាព្យ*

គេធ្វើបុណ្យសព មានអ្វីទាំងគ្រប់ អធិកអធម
ទាំងថ្លៃទាំងថោក តាមគេនិយម អ្នកតូចអ្នកធំ
ឈូឆរតាមគេ។

📖 ប្រយ័ត្នកុំអាន, កុំនិយាយច្រឡំថា អធិករអធ័ម។

**អធិបតេយ្យ** *ន.* (បា.<បធិបត+ភាវ, ដោយអំណាច ឯយ្យ-បច្ច័យ ត្រូវលុប ត របស់ ត ចេញផង់ជា អាធិបតេយ្យ, ក៏ប៉ុន្តែខ្មែរយើងធ្លាប់ប្រើជា អធិបតេយ្យ តាមស្រួលមាត់យូរហើយ) អធិបតីភាព, ភាវៈនៃបុគ្គលជាអធិបតី, ឥស្សរភាព, អំណាចដាច់ខាតលើខ្លួនតាមគន្លងច្បាប់បើកសិទ្ធិឱ្យ :

❖ ប្រទេសឯករាជ្យមានអធិបតេយ្យពេញលក្ខណៈ។

☞ កុំប្រើជា អធិបតេយ្យភាព ឡើយ ដ្បិត អធិបតេយ្យ ប្រែថា "ភាវៈឬភាពនៃ...ជា អធិបតី" ដូចគ្នានឹង អធិបតិភាព ដែរស្រេចទៅហើយ, បើប្រើជា អធិបតេយ្យភាព ត្រូវប្រែថា "ភាពនៃភាពនៃ...ជាអធិបតី", ប៉ុន្តែបើប្រើជា អធិបតីភាព បាន។

❀ បើផ្សំជាមួយនឹងសព្ទឯទៀតត្រូវប្រើជា អាធិបតេយ្យ តាមលំនាំវេយ្យាករណ៍បាលីបានដូចជា :

❖ ធម្មាធិបតេយ្យ

❖ លោកាធិបតេយ្យ

❖ ប្រជាធិបតេយ្យ ជាដើម។

**អនិច្ចកម្ម** *ន.* កម្មមិនទៀង (សេចក្តីស្លាប់) :

❖ ទទួលអនិច្ចកម្ម (*ព.ស.* សម្រាប់សាធារណជនជាគ្រហស្ថ)។

**អនិច្ចធម្ម** *ន.* ធម៌មិនទៀង (សេចក្តីស្លាប់) :

❖ ទទួលអនិច្ចធម្ម (សម្រាប់ប្រើចំពោះតែបព្វជិត)។

**អបលោក** *កិ.* ប្រកាសប្រាប់ឱ្យដឹងរាល់គ្នា :

❖ ប្រកាសប្រាប់គ្នាឱ្យដឹងដើម្បីប្រគល់អ្វីៗឱ្យដល់អ្នកណាមួយ

❖ ប្រកាសសូមអនុញ្ញាតអំពីក្រុមជំនុំក្នុងសន្និបាត។

☙ ខ្មែរប្រើចំពោះតែសេចក្ដីថា "ប្រកាសពាក្យសុំសេចក្ដីយល់ព្រមអំពីជំនុំសង្ឃឬអំពីក្រុមជំនុំដើម្បីបង្វែរឬប្រគល់អ្វីៗឱ្យដល់អ្នកណាមួយ" :

❖ ជំនុំសង្ឃអបលោកបាត្រចីវរឱ្យដល់ភិក្ខុដាច់វស្សា។

**អ៊ុម** ឬ **អ៊ឹម** *កិ.* បៅដោះ (ពាក្យថ្នមដោយទំយើសម្រាប់និយាយរកកូនតូចៗ) :

❖ កូនម៉ែនាងអ៊ុមទៅ។

☙ និយាយថា "ញ៉ុំ, ញ៉ុំដោះ, ញ៉ឹម, ប៊ឹម, អាំ" ក៏មានតាមដោយទម្លាប់ប្រើ។

**អ៊ឺយ** *ឧ.* ពាក្យសម្រាប់កែមស៊ើមប្រើក្នុងកាព្យឬសម្រាប់ស្រែកបង្អូសសំឡេងឱ្យវែងរលាក់រលែកតាមលំនាំបទប្រើក្នុងខាងដើមសង្កាត់ចម្រៀង, ប្រើក្នុងខាងចុងចប់, ប្រើសំឡេងខ្ពស់ជា អ៊ឺ+យ ក៏មានតាមលំនាំសំឡេងដែលត្រូវប្រើ។

☙ *កិ.* (ព.ប្រ.) ទើបតែនឹងផ្ដើមនិយាយ, តាំងផ្ដើមថា, ចេញថា :

❖ គ្រាន់តែ អ៊ឺយ ឡើង គេអាចដឹងបានថាចេះឬល្ងង់ទៅហើយ (ប្រៀបប្រដូចនឹងគេស្រែកច្រៀងថា អ៊ឺយ)។

☞ គួរប្រយ័ត្នក្នុងការប្រើពាក្យថា អ៊ឺយ និងពាក្យ អើយ (អ្អើយ) ក្នុងកាព្យនិងចម្រៀង, គឺកុំថា អ៊ឺយ ជា អើយ ឬ អើយ ជា អ៊ឺយ ឡើយ, ដូចជា

ពាក្យកាព្យថា :

❖ បងអើយម្ដេចឡើយក៏មិនស្ដី... (ត្រូវថា បងអ្ហើយ ឬបងឡ្ហើយ) ទើបចួនគ្នានឹង ឡ្ហើយ, កុំថា បងអឺយ ដែលត្រូវចួនគ្នានឹង ឡើយ, ទៅវិញ។

**កាព្យមានពាក្យ អើយ (អ្ហើយ) ថា**

ឱលោកតាអើយ សុំកុំឆ្លងឆ្លើយ ទៅរកវាអី
ព្រោះវាកោងកាច កំណាចអប្រិយ ក្រោយកុំស្រដី
ទៅរកវាទៀត។

(ត្រូវថា **តាអ្ហើយ** កុំថា **តាអឺយ** ឬ **តាអ៊ុយ**)។

**កាព្យប្រើពាក្យ** អឺយ **ខាងចុងចប់ ថា**

កាព្យនេះប្រែចេញពីបាលី ខ្ញុំរាយសេចក្ដីតាមជើងកាព្យ
ឱ្យចាប់ចួនគ្នាជាដរាប រាបសាចែងចប់ប៉ុណ្ណោះអឺយ។

(ដូចគ្នានឹង...ប៉ុណ្ណោះឯង ឬ ប៉ុណ្ណោះហោង ឬក៏ប៉ុណ្ណោះហើយ ដែរ)។

🕮 ពាក្យ អឺយ នេះចួនកាលប្រើសំឡេងថា អ្ហឺយ ក៏មាន សម្រាប់ស្រែកហៅគ្នាពីចម្ងាយ, ដូចជា :

❖ បងអឺយ! អឺះបង! បងឆ្លើយថា អឺះ!។

☞ បើស្រែកហៅបង្អូសសំឡេងខ្ពស់វែង ត្រូវសរសេរជា អឺ៎យ, អឺ៎ះ ក៏បាន។

**អើយ គឺ** ពាក្យសម្រាប់កែមស៊ែមពីខាងចុងពាក្យ អាលបនៈ ដែលគួរប្រកប ប្រើឱ្យមានសំឡេងវែងស្រួលមាត់, ដូចជា :

- ❖ អ្នកអើយ
- ❖ នាងអើយ
- ❖ សម្លាញ់អើយ
- ❖ ប្អូនអើយ
- ❖ កម្មអើយ
- ❖ យាយអើយ
- ❖ ម្ចាស់អើយ...។

🌹 ពាក្យដែលមានអក្សរប្រកបយ៉ាងនេះថាបានពីរយ៉ាង :

- ❖ អ្នកអ្អើយ
- ❖ នាងអ្អើយ
- ❖ យាយអ្អើយ
- ❖ ម្ចាស់អ្អើយ...។

🌹 ថាតាមសំឡេងប្រកបអក្សរខាងចុងជា :

- ❖ អ្នកកើយ
- ❖ នាងង៉ើយ
- ❖ យាយយ៉ើយ

❖ ម្ចាស់សើយ...ដូច្នេះក៏បាន។

🌹 ប៉ុន្តែបើអក្សរប្រកបដែលផ្សំខ្យល់សំឡេងមិនស្រួលស្តាប់, ដូចជា :

❖ ព្រះអង្គអើយ

❖ ភិក្ខុអើយ

❖ ទុក្ខអើយ

❖ ព្រះពុទ្ធអើយ យ៉ាងនេះត្រូវថាបានតែ អ្អើយ ជាដាច់ខាត កុំថា :

ծ ព្រះអង់គើយ

ծ ភិកខ្ញើយ

ծ ទុកខើយ

ծ ព្រះពុតធើយ ត្រូវថា :

‣ ព្រះអង់អ្អើយ

‣ ភិកអ្អើយ

‣ ទុកអ្អើយ

‣ ព្រះពុតអ្អើយ។

🌹 ឬពាក្យដែលឥតមានអក្សរប្រកប, ដូចជា :

❖ តាអើយ

❖ បាអើយ

❖ មាអើយ

❖ ពូអើយ យ៉ាងនេះក៏ត្រូវថាបានតែ អ្អើយ ដែរ កុំថា :

- តារ៉ើយ
- បារ៉ើយ
- មារ៉ើយ
- ពូរ៉ើយ
- ពូរ៉ើយ ត្រូវថា :

‣ តាអ្អើយ

‣ មាអ្អើយ

‣ ពូអ្អើយ។

+
៘ ប្រើសំឡេងខ្ពស់ជា អើ៊យ ក៏បាន តាមទំនងដែលត្រូវប្រើសូរខ្ពស់។

📖 ត្រូវប្រយ័ត្នកុំប្រើពាក្យ អើយ “អ្អើយ” ជា អឺយ ឬ អ្អឺយ។

**អំណាត់ ៨.** ការអត់ទ្រាំ, សេចក្ដីខំអត់ :

➥ **មានអំណត់** (កុំប្រើថា សេចក្ដីអំណត់ ព្រោះពាក្យនេះជានាមនាមប្រាប់ សេចក្ដីអត់ ស្រេចហើយ; បើចង់ប្រើពាក្យថា ការ, សេចក្ដី ត្រូវថា មានការអត់ ឬ មានសេចក្ដីអត់ ក៏គឺ មានអំណត់ ហ្នឹងឯង)។

➥ **មានអំណត់** កុំប្រើថា មានការអំណត់ ដូច្នេះឡើយ។

➥ **មានអំណត់** កុំប្រើថា មានក្ដីអំណត់ ដូច្នេះឡើយ។

➥ **មានអំណត់** កុំប្រើថា មានសេចក្ដីអំណត់ ដូច្នេះឡើយ។

➢ **អស់អំណាត់** កុំប្រើថា អស់ការអំណត់ ដូច្នេះឡើយ។

➢ **អស់អំណាត់** កុំប្រើថា អស់ក្ដីអំណត់ ដូច្នេះឡើយ។

➢ **អស់អំណាត់** កុំប្រើថា អស់សេចក្ដីអំណត់ ដូច្នេះឡើយ។

*ន.* ដែលមានសេចក្ដីអត់ឃ្លាន, ដែលអត់បាយ :

- គ្រាអំណត់
- ស្រុកអំណត់។

ពាក្យកាព្យ

អំណត់ជានាម កុំបាច់តោងទាម ថែមពាក្យ “សេចក្ដី”
ពុំនោះកុំថែម ស៊ែមពាក្យថា “ក្ដី” មកទៀតធ្វើអ្វី
ឱ្យឃ្លាតចាកបែប។

**អំណរ** *ន.* សេចក្ដីអរ :

➢ **មានអំណរ** (កុំប្រើថា សេចក្ដីអំណរ ព្រោះពាក្យនេះជា នាមនាម សម្រាប់ប្រាប់ដំណើររបស់កិរិយាសព្ទ អរ ស្រេចហើយ; បើចង់ប្រើពាក្យថា សេចក្ដី ត្រូវថា មានសេចក្ដីអរ ក៏គឺ មានអំណរ ហ្នឹងឯង)។

➢ **មានអំណរ** កុំប្រើថា មានការអំណរ ដូច្នេះឡើយ។

➢ **មានអំណរ** កុំប្រើថា មានក្ដីអំណរ ដូច្នេះឡើយ។

➢ **មានអំណរ** កុំប្រើថា មានសេចក្ដីអំណរ ដូច្នេះឡើយ។

➢ **អស់អំណរ** កុំប្រើថា អស់ការអំណរ ដូច្នេះឡើយ។

➢ **អស់អំណរ** កុំប្រើថា អស់ក្ដីអំណរ ដូច្នេះឡើយ។

➢ **អស់អំណរ** កុំប្រើថា អស់សេចក្ដីអំណរ ដូច្នេះឡើយ។

ពាក្យកាព្យ

ពាក្យថា អំណរ ជានាមនៃអរ ជាកិរិយាសព្ទ
ចេញមកជានាម ប្រើតាមប្រញ្ញត្តិ វេយ្យាករណ៍ប្រាប់
ឱ្យប្រើស្រេចហើយ។

កុំថែមពាក្យថ្មី ថា "មានសេចក្ដី- អំណរ" ច្នេះឡើយ
ព្រោះកាលបើថែម ស៊ើមលើសបែបហើយ នឹងទៅជាល្ពើយ
ខុសពីរបៀប។

**អំណោយ** *ន.* ការឱ្យ; អ្វីៗដែលឱ្យ។

📖 កុំប្រើថា សេចក្ដីអំណោយ, ការអំណោយ, របស់អំណោយ ដូច្នេះឡើយ; ប៉ុន្តែបើប្រើជា របស់ជាអំណោយ ដូច្នេះបាន។

**អំណោយផល** : ផលទាន។

*គុ.* មានអំណោយផល។

**ទទួលអំណោយ** : ទទួលរបស់ដែលគេឱ្យដោយសទ្ធា។

**ធ្វើអំណោយ** : ឱ្យអ្វីៗដោយសទ្ធា។

📖 កុំប្រើជា សេចក្ដីអំណោយ, ការអំណោយ ដូច្នេះឡើយ; ប៉ុន្តែបើប្រើស្មើរជា *គុ.* ថា របស់អំណោយ ដូច្នេះបានជាជំនួស របស់ជាអំណោយ។

- **មានអំណោយ** កុំប្រើថា មានការអំណោយ ដូច្នេះឡើយ។
- **មានអំណោយ** កុំប្រើថា មានក្ដីអំណោយ ដូច្នេះឡើយ។
- **មានអំណោយ** កុំប្រើថា មានសេចក្ដីអំណោយ ដូច្នេះឡើយ។
- **អស់អំណោយ** កុំប្រើថា អស់ការអំណោយ ដូច្នេះឡើយ។
- **អស់អំណោយ** កុំប្រើថា អស់ក្ដីអំណោយ ដូច្នេះឡើយ។
- **អស់អំណោយ** កុំប្រើថា អស់សេចក្ដីអំណោយ ដូច្នេះឡើយ។

📖 មួយវិញទៀតគួរកុំប្រើ ***កិ.*** តាមសៀម ព្រោះសៀមយកពាក្យខ្មែរថា **អំណោយ** ***ន.*** នេះទៅប្រើជា ***កិ.*** ថា អាំនួយ ***អ.ឲ.*** អាំនួយ គេប្រែថា អួយ ***អ.ឲ.*** អួយ "ឱ្យ" ទីទៃពីខ្មែរស្រលះផង។

**អំនួត** ***ន.*** ការពោលអួតឬសម្ដីអួត :

- **មនុស្សមានអំនួត** : មនុស្សអ្នកអួត។

📖 កុំប្រើថា សេចក្ដីអំនួត, បើត្រូវការប្រើពាក្យថា សេចក្ដី ត្រូវថា សេចក្ដីអួត ក៏គឺ អំនួត ហ្នឹងឯង។

- **មានអំនួត** កុំប្រើថា មានការអំនួត ដូច្នេះឡើយ។
- **មានអំនួត** កុំប្រើថា មានក្ដីអំនួត ដូច្នេះឡើយ។
- **មានអំនួត** កុំប្រើថា មានសេចក្ដីអំនួត ដូច្នេះឡើយ។
- **អស់អំនួត** កុំប្រើថា អស់ការអំនួត ដូច្នេះឡើយ។
- **អស់អំនួត** កុំប្រើថា អស់ក្ដីអំនួត ដូច្នេះឡើយ។

➢ **អស់អំនួត** កុំប្រើថា អស់សេចក្ដីអំនួត ដូច្នេះឡើយ។

**ពាក្យកាព្យ**

អំនួតជានាមសព្ទ មានបែបប្រាប់ថាកុំប្រើ-
"សេចក្ដី" ថែមស៊ើមលើ ទាំងកុំប្រើ "ក្ដី" ផ្សំឡើយ។៚

**អំពល់** *ន.* កង្វល់ឬសេចក្ដីខ្វល់ចិត្ត, ដំណើរដែលនាំឱ្យមានរវល់ខ្វល់ចិត្ត :

➢ **មានអំពល់** កុំប្រើថា មានការអំពល់ ដូច្នេះឡើយ។

➢ **មានអំពល់** កុំប្រើថា មានក្ដីអំពល់ ដូច្នេះឡើយ។

➢ **មានអំពល់** កុំប្រើថា មានសេចក្ដីអំពល់ ដូច្នេះឡើយ។

➢ **អស់អំពល់** កុំប្រើថា អស់ការអំពល់ ដូច្នេះឡើយ។

➢ **អស់អំពល់** កុំប្រើថា អស់ក្ដីអំពល់ ដូច្នេះឡើយ។

➢ **អស់អំពល់** កុំប្រើថា អស់សេចក្ដីអំពល់ ដូច្នេះឡើយ។

**នាំអំពល់** : នាំឱ្យមានអំពល់។

**កុំអំពល់!** *និ.* កុំរវល់!, កុំអើពើ! :

❖ កុំអំពល់! តាមតែគេចុះ!។

**អំពល់អី!** : រវល់អី។

**អំពល់ទុក្ខ** : មានទុក្ខ...។

**ឱកាស** *និ.* ពាក្យគោរពសម្រាប់ផ្ដើមមុនបង្អស់ក្នុងវេលារៀបនឹងសូមអ្វីៗឬប្រកាសសេចក្ដីណាមួយ, ដោយសេចក្ដីថា :

❖ សូមគោរព!

❖ សូមទាន!

❖ សូមទានគោរព!

❖ សូមមេត្តា!

❖ សូមមេត្តាប្រោស!

❖ ទានប្រោស!

❖ សូមទានប្រោស!

☞ (សម្រាប់ប្រើតែខាង សាសនា តាមសេចក្តីពេញចិត្តឬធ្លាប់ប្រើ)។

**ឱ្យ** *កិ.* (ជាអញ្ញត្រសព្ទដោយអនុវត្តតាមការពិភាក្សា ហើយសម្រេចនៃគណៈកម្មការរៀបរៀង វចនានុក្រមខ្មែរ គ្រាដំបូងបំផុតក្នុងកាល ព.ស. **២៤៥៩** គ.ស. **១៩១៥** ថាត្រូវប្រើជា ឱ្យ យ៉ាងនេះ មិនយល់ព្រមឱ្យប្រើជា ឲ្យ ឬ អោយ ឡើយ)។

❀ ធ្វើអំណោយ គឺលះអ្វីៗដល់អ្នកដទៃ :

❖ ឱ្យប្រាក់

❖ ឱ្យស្បៀង

❖ ឱ្យទ្រព្យរបស់

❖ ឱ្យគ្រឿងស្លៀកពាក់។

❀ ប្រើ, បង្គាប់, ញុំាង :

❖ ឱ្យធ្វើ

❖ ឱ្យទៅ

❖ ឱ្យមក។

**ឱ្យកាន់ការ** : ឱ្យទទួលកាន់មុខការ។

**ឱ្យការណ៍** : ប្រាប់ណើរការណ៍, ប្រាប់រឿងហេតុ :

❖ សាក្សីឆ្លើយឱ្យការណ៍តាមពិត។

**ឱ្យជើង** : ហុចជើងម្ខាងឱ្យចាប់ :

❖ អ្នកចំបាប់ឱ្យជើងគ្នាម្ដងម្នាក់។ លើកជើងហុចបញ្ឆោះឬបញ្ឈឺចិត្តចំពោះមុខដោយសេចក្ដីព្រហើនមើលងាយ :

*ឧ.* វាប៉ានឱ្យជើងខ្ញុំ។

**ឱ្យដៃ** : បើកដៃឱ្យប៉ានធ្វើ។ ហុចដៃបញ្ឆោះដោយសេចក្ដីមើលងាយឬក៏ហុចដៃចំអកឡក់ឱ្យគ្នា :

❖ វាប៉ានឱ្យដៃខ្ញុំ

❖ អ្នកច្រៀងតឱ្យដៃគ្នា (និយាយថា ហុចដៃឱ្យគ្នាក៏បាន)។

**ឱ្យដំណឹង** : ប្រាប់ដំណឹង។

**ឱ្យតម្រួយ** : ប្រាប់តម្រួយ។

**ឱ្យន័យ** : ពន្យល់។

- **ឱ្យនាម** : សន្មតនាមឬតាំងនាម។
- **ឱ្យឈ្មោះ** : សន្មតឈ្មោះឬតាំងឈ្មោះ។
- **ឱ្យឧបាយ** : ប្រាប់ឧបាយ។
- **ឱ្យអំណាច** : បើកអំណាច, ប្រគល់អំណាច។

*៧.ក.* បញ្ជាក់អញ្ញត្រសព្ទថា :

- អញ
- អ្នក
- នេះ
- នោះ
- ឱ្យ
- ហោង។

កុំឱ្យសរសេរតាមសូរថា :

- អាញ់
- នាក់
- និះ
- នុះ
- ឱយ
- អ្នូង។

ពាក្យកាព្យ

| | | |
|---|---|---|
| វីពាក្យអញអ្នក | នេះនោះបញ្ជាក់ | ដល់ឱ្យនិងហោង |
| ពោលជាពាក្យកាព្យ | ឱ្យងាយចាំចង | សរសេរម្តងៗ |
| | កុំភ្លាត់តាមសូរ។៚ | |
| ប៉ុណ្ណោះជាអាទិ | ប្រើកុំឱ្យឃ្លាត | យកផ្សេងជាថ្នូរ |
| អញ្ញត្រសព្ទ | មិនត្រូវផ្លាស់ប្តូរ | ទោះបីមានសូរ |
| | ឮផ្សេងក៏ដោយ។៚ | |

**ឯករាជ** *ន.* ឬ *គុ.* ស្តេចឯក; ដែលមានស្តេចសោយរាជ្យឬអ្នកគ្រប់គ្រងប្រទេសមួយមិនជាចំណុះប្រទេសណា។

**ឯករាជ្យ** *ន.* រាជ្យឯក, រាជ្យនៃស្តេចឯក; ភាពនៃរដ្ឋឬប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូរក្នុងការគ្រប់គ្រងខ្លួនឯង មិនមែនជាចំណុះរបស់ប្រទេសដទៃ :

- ការពារឯករាជ្យ
- គ្រប់គ្រងឯករាជ្យ។

**ឡូក១** *ទុ.ស.* (ពាក្យខ្មែរបុរាណព្រេងព្រឹទ្ធ សព្វថ្ងៃនេះប្រើជា អញ្ញត្រសព្ទ) ពាក្យប្រើជាជំនួស ឈ្មោះបុគ្គល ដែលត្រូវនិយាយទៅរកក្នុងទីចំពោះមុខសម្រាប់ប្រជាពលរដ្ឋហៅគ្នាដោយសេចក្តីគួរសម មិនចេញឈ្មោះបុគ្គលនោះ (ប្រើបានទាំងប្រុសទាំងស្រី) :

❖ អ្នកអញ្ជើញទៅណា? អញ្ជើញអ្នកចូលអង្គុយលេងសិន! អ្នកស្រី សុខសប្បាយទេឬ?។

សាធារណជនហៅបងថ្លៃ ក៏ប្រើ អ្នក ដែរ។

ប្រើជាពាក្យនាំមុខឈ្មោះបុគ្គលក៏បាន :

❖ អ្នកចន្ទ

❖ អ្នកទេព

❖ អ្នកនន្ទ

❖ អ្នកសុខ។

ទំនៀមសាធារណជនខ្មែរក្នុងសម័យពីដើម មុនសម័យបច្ចុប្បន្ននេះ :

បើបុរសណាបានបួសជាភិក្ខុហើយសឹកមក ត្រូវហៅ អ្នក :

❖ អ្នកសម

❖ អ្នកសោម។

បើបានបួសជាសាមណេរហើយសឹកមក ត្រូវហៅ ជី :

❖ ជីមាស

❖ ជីមិត្រ។

បើមិនបានបួសសោះទេត្រូវហៅ ចៅ :

❖ ចៅប្រាក់

❖ ចៅមាស។

✍ បើនៅជំទង់ឬកំលោះហៅ អ្នក។

📖 ដោយហេតុនេះទើបមានពាក្យចាស់ទុំខ្លះនិយាយបង្អាប់គ្នាថា បួសឱ្យតែព្រះពុទ្ធឱ្យងារ គឺបួសហើយសឹកមកគ្មានចេះអ្វី បួសយកតែងារ អ្នក ឬ ឌី ប៉ុណ្ណោះ។

**អ្នក២** *ន.* (ជាអញ្ញត្រសព្ទ) បុគ្គល, ជន, មនុស្ស។

❀ ពាក្យសម្រាប់នាំមុខសព្ទដទៃ, ប្រើបានតាមគួរ, ដូចជា :

- **អ្នកការ** : បុគ្គលដែលធ្វើការឬកាន់ការ, អ្នកកាន់ការ, អ្នកធ្វើការ។
- **អ្នកកីឡា** : បុគ្គលដែលលេងល្បែងកម្សាន្តចិត្ត។
- **អ្នកក្រ** : ជនដែលក្រទ្រព្យ។
- **អ្នកក្រុង** : ជនដែលនៅក្នុងក្រុង។
- **អ្នកក្លាហាន** : បុគ្គលក្លាហាន។
- **អ្នកខ្លាច** : ជនដែលខ្លាច។
- **អ្នកខ្លៅ** : បុគ្គលខ្លៅ។
- **អ្នកខ្លះ** : ជនខ្លះ។
- **អ្នកត្រូ** : ជនដែលចម្អិនភោជនាហារ (អាវាលិក, អាឡារិក)។
- **អ្នកចេះ** : បុគ្គលមានចំណេះ។
- **អ្នកចោទ** : បុគ្គលដែលចោទប្រកាន់ឬអ្នកដែលដាក់ចំណោទ។
- **អ្នកចម្ការ** : មនុស្សដែលធ្វើចម្ការ។

- **អ្នកឆ្លើយ** : ជនអ្នកឆ្លើយ។
- **អ្នកជា** : ភុជិស្សជន។
- **អ្នកជំនួញ** : ជនដែលធ្វើជំនួញ។
- **អ្នកឈ្លប** : ជនដែលឈ្លប។
- **អ្នកដឹង** : ជនដែលដឹង។
- **អ្នកតូច** : បុគ្គលដែលតូចជាងគេ។
- **អ្នកទាប** : បុគ្គលដែលទាបថោក។
- **អ្នកទេសន៍** : បព្វជិតដែលចេះទេសន៍ (ធម្មកថិក)។
- **អ្នកធំ** : បុគ្គលជាធំ (ឥស្សរជន)។
- **អ្នកបួស** : ជនដែលបួស (បព្វជិត)។
- **អ្នកប្រាជ្ញ** : បុគ្គលដែលមានប្រាជ្ញាស្គាល់ខុសត្រូវ។
- **អ្នកផ្សារ** : ជនដែលមានផ្ទះលំនៅក្នុងប្រជុំផ្សារឬជនដែលលក់ទំនិញក្នុងផ្សារ។
- **អ្នកព្រៃ** : ជនដែលនៅក្នុងស្រុកព្រៃ។
- **អ្នកភ្លេង** : មនុស្សដែលចេះភ្លេងឬដែលលេងភ្លេង។
- **អ្នកមាន** : អ្នកដែលមានទ្រព្យច្រើន។
- **អ្នករក** : ជនដែលរក; ជនដែលខំប្រឹងធ្វើការរកស៊ី។
- **អ្នករាជការ** : មនុស្សដែលធ្វើរាជការ។

**អ្នករៀន** : ជនដែលកំពុងរៀន, សិស្សរៀន។

**អ្នកលេង** : ជនដែលលេងល្បែង; ជនដែលប្រព្រឹត្តតែខាងការលេង...(មានច្រើនប្រភេទ)។

**អ្នកស៊ើប** : ជនដែលស៊ើបការណ៍។

**អ្នកស្រុក** : ជនដែលនៅក្នុងស្រុក; ពួកជនក្នុងស្រុកនីមួយៗ។

**អ្នកស្រែ** : ជនដែលធ្វើស្រែ។

## សូមគោរពប្រគេន ជូនដំណឹងចំពោះ

ព្រះតេជព្រះគុណ ឯកឧត្តម លោកជំទាវ បញ្ញវន្ត លោកគ្រូ អ្នកគ្រូ និស្សិតទាំងអស់ មេត្តាជួយកែតម្រូវនិងកែលម្អអត្ថន័យខ្លឹមសារក្នុងគំនិតស្ថាបនាជ្រះថ្លាតាមការគួរដោយក្តីអនុគ្រោះ!

ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពថ្លែងអំណរព្រះគុណ អរគុណ និងកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុត!

ចំពោះទឹកព្រះទ័យ ទឹកចិត្តប្រកបដោយកុសលចេតនាជ្រះថ្លា!

**ទូរសព្ទលេខ** : **០១២ ៦២ ៧០ ៧០**

: **០៩២ ៤៧ ៦៦ ២២**

## ឯកសារយោង

១- **ជួន-ណាត** វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១-២៥១២ គ.ស. ១៩៦៧-១៩៦៨, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

២- ព្រឹត្តិបត្រលេខ១ ២០០៨ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ

៣- ព្រឹត្តិបត្រលេខ២ ២០០៩ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ

៤- ព្រឹត្តិបត្រលេខ៣ ២០១០ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ

៥- ព្រឹត្តិបត្រលេខ៤ ២០១២ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

៦- ព្រឹត្តិបត្រលេខ៥ ២០១៣ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

៧- សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍ខ្មែរ-អង់គ្លេស-បារាំង២០១៣ ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

៨- ឈ្មោះប្រទេសនិងរាជធានីរដ្ឋធានី២០១៣ ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

៩- **ច័ន្ទ សំណាញ** (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១០- **ច័ន្ទ សំណាញ** (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១១- **ច័ន្ទ សំណាញ** (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១២- **ច័ន្ទ សំណាញ**(២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ **ភារ** និងផ្នត់ដែក [-**រម/ណា**-] / [-**រឹម/ន**-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១៣- ព្រះគ្រូមុនីសោភ័ណ **សេខ-នាខ** សារញ្ញាណោ,បាលីវេយ្យាករណ៍, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៤៤ គ. ស. ២០០០

១៤- ព្រះគ្រូសិរីសោភ័ណ **ភិម-តូ**, បទានុក្រមធម្មបទភាគទី១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៥- ព្រះគ្រូសិរីសោភ័ណ **ភិម-តូ**, បទានុក្រមធម្មបទភាគទី២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៦- ព្រះគ្រូសិរីសោភ័ណ **ភិម-តូ**, បទានុក្រមធម្មបទភាគទី៣, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៧- **អៀង-ភើស** ភាសាខ្មែរ

១៨- វចនានុក្រមខ្មែរ KHMER DICTIONARY, ការផ្សាយបណ្ណាគារអង្គរធំ ព. ស. ២៥៥៥ គ. ស. ២០១១

១៩- ធាតុសង្គ្រោះ

២០- សទ្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

២១- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ

២២- **ហ៊ីង-ឌីឫទ្ធិ** អត្ថាធិប្បាយវចនានុក្រមច្បាប់

## ជីវប្រវត្តិ

ខ្ញុំ **ទូច-គីមស្រ៊ាង** កើតនៅឆ្នាំ១៩៧៤ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ ជាកូនទី៥ ក្នុងចំណោមបងប្អូនប្រុសស្រី៦នាក់ ស្រី៤ ប្រុស២

ឪពុកឈ្មោះ **រី-យេន** ស្លាប់

ម្តាយឈ្មោះ **អ៊ី-មាស** ស្លាប់

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្តេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្មវិធីពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ពណ្ណាលោម

ISBN-13 : 978-99963-705-5-7

9 789996 370557